# ច្បាប់

# ស្តីពី

# ការបោះឆ្នោតជ្រើសរើស

# ក្រុមប្រឹក្សាឃុំ សង្កាត់

/ រកម / ០៣០១ / ០៤

[illegible]
លេខ: ៥០៥...............
ថ្ងៃ ... ឆ្នាំ២០០១. ម៉ោង ...
បញ្ជូនទៅ. [illegible]...........

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១៤ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤២ /០០៤/ ២០០១ កបធ.ច ចុះថ្ងៃទី ០៧ ខែ មិនា ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលបំណងកំណត់ការរៀបចំ ការគ្រប់គ្រងនិងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ច្បាប់នេះត្រូវអនុវត្តចំពោះឃុំ សង្កាត់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ស្របទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ។

មាត្រា ៣.-

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងរៀងរាល់៥ឆ្នាំម្តង។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវរៀបចំធ្វើឡើងនៅថ្ងៃជាមួយគ្នា ។

កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ការបោះឆ្នោតត្រូវធ្វើនៅថ្ងៃអាទិត្យ តែមួយថ្ងៃ ។

មាត្រា ៤.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវកាន់កាប់មុខតំណែងរបស់ខ្លួនរហូតទាល់តែមានក្រុមប្រឹក្សាថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស ។

មាត្រា ៥.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ដោយអ្នកបោះឆ្នោតដែល :

- បានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ

- មានសិទ្ធិបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការបោះឆ្នោតជាសម្ងាត់ ។

អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តែមួយប៉ុណ្ណោះ។

មាត្រា ៦.-

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗដូចដែលបានចែងក្នុងមាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យក្នុងរយៈពេលយ៉ាងតិច ៩ខែ មុនថ្ងៃបោះឆ្នោត ។

## ជំពូកទី ២
## ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា ៧.-

ការចាត់ចែងរៀបចំនិងគ្រប់គ្រងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានបង្កើតឡើងតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោតត្រូវមានការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត និងការិយាល័យបោះឆ្នោត ។

សមាសភាពការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនិងការិយាល័យបោះឆ្នោត ត្រូវតែងតាំងឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៨.-

សមាជិកនិងមន្ត្រីគ្រប់រូបនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ការិយាល័យចុះ

ឈ្មោះអ្នកបោះឆ្នោតនិងការិយាល័យបោះឆ្នោត ត្រូវប្រកាន់ជំហរឯករាជ្យមិនលម្អៀងនិងស្មោះត្រង់ក្នុងការអនុវត្តអំណាច មុខងារ ភារកិច្ចរបស់ខ្លួន ។

មាត្រា ៩.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវដាក់ចេញនូវបទបញ្ជានិងនីតិវិធីផ្សេងៗសម្រាប់ចាត់ចែងរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត និងការបោះឆ្នោតផ្អែកតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ ។

មាត្រា ១០.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានអំណាច មុខងារនិងភារកិច្ចដូចខាងក្រោម :

- រៀបចំចាត់ចែងការងារផ្សេងៗសម្រាប់ចុះឈ្មោះអ្នកបោះឆ្នោត ធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត រៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់
- ចាត់វិធានការចាំបាច់ដើម្បីធានាឱ្យការចុះឈ្មោះអ្នកបោះឆ្នោត ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌
- កំណត់និងរៀបចំបង្កើតការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត
- រៀបចំនិងផ្តល់សុពលភាពលើបញ្ជីឈ្មោះអ្នកបោះឆ្នោត
- ពិនិត្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជារៀងរាល់ឆ្នាំ
- ការពារសុវត្ថិភាពនិងរក្សាបញ្ជីឈ្មោះអ្នកបោះឆ្នោត
- សម្រេចលើការចុះបញ្ជីបេក្ខជន
- ពិនិត្យតាមដានយុទ្ធនាការឃោសនាបោះឆ្នោត
- គ្រប់គ្រងនីតិវិធីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត
- គ្រប់គ្រងនីតិវិធីរាប់សន្លឹកឆ្នោតនិងចាត់ចែងការរាប់សន្លឹកឆ្នោត
- ប្រកាសលទ្ធផលនៃការបោះឆ្នោត
- ការពារសុវត្ថិភាពក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត ដំណើរការចុះឈ្មោះ

អ្នកបោះឆ្នោត ដំណើរការបោះឆ្នោត ដំណើរការរាប់សន្លឹកឆ្នោតនិងការពារសុវត្ថិភាព សម្ភារៈ ឧបករណ៍ គ្រឿងសង្ហារឹមសម្រាប់ដំណើរការបោះឆ្នោតទាំងមូល

- បណ្តុះបណ្តាលមន្ត្រីបោះឆ្នោតនិងណែនាំដល់បេក្ខជន ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អំពីនីតិវិធីផ្សេងៗសម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោតនិងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ

- ធានាឱ្យសាធារណជនទូទៅមានការយល់ដឹងអំពីគោលបំណងនៃការបោះឆ្នោត

- ធានាឱ្យជនគ្រប់រូបមានសិទ្ធិចូលរួមប្រកបដោយសុវត្ថិភាពនិងគ្មានការភ័យខ្លាច ឬការបំភិតបំភ័យក្នុងដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ចុះឈ្មោះអ្នកបោះឆ្នោតនិងការបោះឆ្នោត

- រៀបចំនីតិវិធីនៃការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត ការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោតប្រកបដោយតម្លាភាព និងដោយមានការចូលរួមពីអ្នកសង្កេតការណ៍និងភ្នាក់ងារនៃគណបក្សនយោបាយ

- ធានាឱ្យមានទំនាក់ទំនងទៀងទាត់រវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាមួយបេក្ខជនភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍

- អនុវត្តតាមការកំណត់និងនីតិវិធីផ្សេងៗដែលទាក់ទងដល់ការត្រួតពិនិត្យ ការគ្រប់គ្រងហិរញ្ញវត្ថុដែលរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- សម្រេចលើបណ្តឹងតវ៉ាទាក់ទងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ លើកលែងតែបណ្តឹងតវ៉ាទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ

- ធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភានិងព្រឹទ្ធសភា ស្តីពីការគ្រប់គ្រង ការប្រព្រឹត្តទៅនិងលទ្ធផលនៃការបោះឆ្នោត ក្នុងអំឡុងពេល ៩០ (កៅសិប)ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។

អំណាច មុខងារនិងភារកិច្ចដូចមានចែងក្នុងមាត្រា ៧ ៨ ៩ និងមាត្រា ១០ នៃច្បាប់នេះត្រូវបន្ថែមទៅលើអំណាច មុខងារនិងភារកិច្ចដែលបានតម្រូវ ឬបានប្រគល់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

មាត្រា ១១.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងសមាជិកគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត មន្ត្រីការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនិងមន្ត្រីការិយាល័យបោះឆ្នោតពីក្នុងចំណោមប្រជាពលរដ្ឋ មន្ត្រីរាជការ ឬអ្នកមុខអ្នកការក្នុងខេត្ត ក្រុង ដែលមានសិទ្ធិបោះឆ្នោត លើកលែងតែ :

- កងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ
- ព្រះសង្ឃឬបុព្វជិតនៃសាសនាណាមួយ
- ប្រតិភូរាជរដ្ឋាភិបាល អភិបាលឬអភិបាលរងខេត្ត ក្រុង
- អភិបាល ឬ អភិបាលរងស្រុក ខ័ណ្ឌ
- មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង មេភូមិ អនុប្រធានភូមិនិងសមាជិកភូមិ
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- បេក្ខជនដែលកំពុងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ជនដែលកំពុងមានមុខតំណែងនៅក្នុងគណបក្សនយោបាយ ឬបានឈប់ពីមុខតំណែងនៅក្នុងគណបក្សនយោបាយណាមួយ ក្នុងរយះពេលតិចជាង ៦ (ប្រាំមួយ)ខែ គិតមកដល់ថ្ងៃតែងតាំង ។

មាត្រា ១២.-

សមាសភាពគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតរួមមាន ប្រធានម្នាក់ អនុប្រធានម្នាក់និងសមាជិកពី៣ (បី) ទៅ ៥(ប្រាំ) នាក់ ។

សមាសភាពគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតរួមមាន ប្រធានម្នាក់ អនុប្រធានម្នាក់និងសមាជិក៣(បី) នាក់ ។

សមាសភាពការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតរួមមានប្រធានម្នាក់ អនុប្រធានម្នាក់ លេខាធិការម្នាក់ និងដែលមានសមាជិកពី ២ (ពីរ)នាក់ទៅ ៤(បួន)នាក់ អាស្រ័យដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាអ្នកកំណត់ សម្រាប់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនីមួយៗ ។

សមាសភាពការិយាល័យបោះឆ្នោតរួមមាន ប្រធានម្នាក់ អនុប្រធានម្នាក់ លេខាធិការម្នាក់និងដែលមានសមាជិកពី ២(ពីរ)នាក់ ទៅ៤ (បួន)នាក់ អាស្រ័យដោយគណៈកម្មាធិការ

ជាតិរៀបចំការបោះឆ្នោតជាអ្នកកំណត់ សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ។

សមាជិកគ្រប់រូបរបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ មន្ត្រីនៃការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនិងមន្ត្រីនៃការិយាល័យបោះឆ្នោតគឺជាមន្ត្រីបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចបង្កើតនិងចាត់តាំងលេខាធិការដ្ឋានមួយជាជំនួយការឱ្យគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតនិងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

មាត្រា ១៣.-

ឋានៈ បុព្វសិទ្ធិនិងប្រាក់បំណាច់របស់ប្រធាន អនុប្រធាន សមាជិកនិងអគ្គលេខាធិការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនិងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ព្រមទាំងបុគ្គលិកទាំងអស់ត្រូវបានកំណត់ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៣០ និងមាត្រា ៣១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

មាត្រា ១៤.-

សមាសភាពការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតត្រូវស្ថិតក្នុងមុខតំណែង ទៅតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

សមាសភាពការិយាល័យបោះឆ្នោតត្រូវស្ថិតនៅក្នុងមុខតំណែង រហូតដល់ថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការិយាល័យរបស់ខ្លួននិងក្រោយពីបានប្រគល់ ទទួលកំណត់ហេតុនៃការបោះឆ្នោតព្រមទាំងសម្ភារៈឧបករណ៍បោះឆ្នោតចប់សព្វគ្រប់ឱ្យគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវស្ថិតនៅក្នុងមុខតំណែង រហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងឃុំ សង្កាត់របស់ខ្លួន ។

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវស្ថិតនៅក្នុងមុខតំណែង រហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងខេត្ត ក្រុងរបស់ខ្លួន ។

មាត្រា ១៥.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធប្រគល់អំណាច មុខងារ ភារកិច្ចណាមួយរបស់ខ្លួនតាមបទបញ្ជា ទៅឱ្យគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ការិយាល័យបោះឆ្នោត ឬមន្ត្រីបោះឆ្នោតណាម្នាក់ដែលបានទទួលការតែងតាំង ។

សេចក្តីយោងណាមួយក្នុងច្បាប់នេះទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក៏ត្រូវយោងផងដែរទៅដល់សមាជិកនៃគណៈកម្មការ ឬមន្ត្រីបោះឆ្នោតណាម្នាក់ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រគល់អំណាច មុខងារនិងភារកិច្ចឱ្យ ។

មាត្រា ១៦.-

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ការិយាល័យបោះឆ្នោតត្រូវបំពេញមុខងារ ភារកិច្ចនិងអំណាចផ្សេងៗ ដែលច្បាប់នេះ ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រគល់ឱ្យ ។

មាត្រា ១៧.-

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវចំពោះការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនិងការងារដទៃទៀត ត្រូវផ្តល់កិច្ចសហការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនិងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ព្រមទាំងការិយាល័យបោះឆ្នោត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខនិងសណ្តាប់ធ្នាប់ សាធារណៈក្នុងសម័យបោះឆ្នោតនិងក្រោយសម័យបោះឆ្នោត ។

មាត្រា ១៨.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិតែងតាំងគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ឬគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ឬសមាសភាពការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ឬសមាសភាពការិយាល័យបោះឆ្នោតក្នុងរយៈពេលមានកំណត់ នៅពេលណាមួយបន្ទាប់ពីការបោះឆ្នោត ក្នុងគោលបំណងគ្រប់គ្រងនិងចាត់ចែងការបោះឆ្នោតឡើងវិញ ឬបោះឆ្នោតសាជាថ្មី ឬធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងចុះឈ្មោះអ្នកបោះឆ្នោត ។

# ជំពូកទី ៣
## សិទ្ធិចុះឈ្មោះនិងសិទ្ធិបោះឆ្នោត

មាត្រា ១៩.-

ដើម្បីមានសិទ្ធិបោះឆ្នោត ប្រជាពលរដ្ឋទាំងពីរភេទត្រូវមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងមានប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត ។

ដើម្បីមានសិទ្ធិចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

- មានសញ្ជាតិខ្មែរ
- មានអាយុ ១៨ ឆ្នាំឡើង គិតមកទល់ថ្ងៃបោះឆ្នោត
- មានទីលំនៅក្នុងឃុំ សង្កាត់ដែលសាមីខ្លួនកំពុងសុំចុះឈ្មោះ
- មិនស្ថិតក្នុងស្ថានភាពណាមួយដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់នេះ

ទីលំនៅរបស់ជនណាម្នាក់ក្នុងឃុំ សង្កាត់ណាមួយ គឺជាទីកន្លែងដែលជននោះធ្លាប់រស់នៅជាធម្មតា ហើយតែងតែវិលត្រលប់មកទីកន្លែងនោះវិញ បន្ទាប់ពីអវត្តមានជាបណ្ដោះអាសន្នមួយរយៈមក ។

មាត្រា ២០.-

ហាមចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រសិនបើជននោះ :

- ជាទណ្ឌិត
- ជាជនវិកលចរិតឬជាជនដែលស្ថិតនៅក្រោមអាណាព្យាបាល ដែលមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

## ជំពូកទី ៤
## ប្រព័ន្ធបោះឆ្នោតនិងការបែងចែកអាសនៈ

មាត្រា ២១.-

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ដោយបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត ដូចមានចែងក្នុងមាត្រា ២៣ និងមាត្រា ២៧ នៃច្បាប់នេះ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសចេញពីក្នុងបញ្ជីបេក្ខជនរបស់គណបក្សនយោបាយ ដែលត្រូវបានជាប់ឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ។

មាត្រា ២២.-

ចំនួនអាសនៈនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវស្មើគ្នានឹងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានកំណត់ដោយអនុក្រឹត្យ អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

មាត្រា ២៣.-

អាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបែងចែកដោយផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោត តាមជំហានទាំងឡាយដូចខាងក្រោម ÷

**ជំហានទីមួយ :** កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈមួយ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបមកចែកនឹងចំនួនអាសនៈសរុបរបស់ក្រុមប្រឹក្សា តាមរូបមន្តដូចខាងក្រោម :

$$ក_{ត} = \frac{ស_{ស}}{អ_{ស}}$$

ក្នុងនោះ :

- $ក_{ត}$ : តាងឱ្យកូតាជាផលចែកដោយមិនគិតសំណល់ចែក
- $ស_{ស}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

- $អ_{ស}$ : តាងឱ្យចំនួនអាសនៈសរុបនៅក្នុងក្រុមប្រឹក្សា ។

**ជំហានទីពីរ** : កំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល ដោយយកចំនួនសន្លឹកឆ្នោតបានការ ដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួលមកចែកនឹងកូតា តាមរូបមន្តដូចខាងក្រោម :

$$អ_{ន} = \frac{ស_{ប}}{ក_{ត}}$$

ក្នុងនោះ :

- $អ_{ន}$ : ជាផលចែកដោយមិនគិតសំណល់ចែក តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗមានសិទ្ធិទទួលបាន មុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយនៅក្នុងជំហានទីបី
- $ស_{ប}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ
- $ក_{ត}$ : តាងឱ្យកូតាដែលបានកំណត់នៅក្នុងជំហានទីមួយ ។

បន្ទាប់ពីគណនាគ្រប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ក្នុងជំហានទី២ហើយ ប្រសិនគ្មានអាសនៈនៅសល់ដើម្បីបែងចែកបន្តទៀតនោះ ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង ។

ក្នុងករណីមានអាសនៈនៅសល់ត្រូវបន្តបែងចែក បន្ទាប់ពីធ្វើការគណនាសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ អាសនៈដែលនៅសល់ទាំងនេះត្រូវផ្តល់ឱ្យទៅតាមរបៀបដែលបានកំណត់ក្នុងជំហានទីបី ។

**ជំហានទីបី** : អាសនៈដែលនៅសល់ត្រូវបែងចែកដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមរូបមន្តដូចខាងក្រោម :

$$ម_{ធ} = \frac{ស_{ប}}{អ_{ន}+១}$$

ក្នុងនោះ :

- $ម_{ធ}$ : តាងឱ្យមធ្យមភាគខ្ពស់បំផុត

- ស្ប ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ

- អ្ន ៖ តាងឱ្យចំនួនអាសនៈដែលបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។

ក្នុងករណីនៅសល់អាសនៈចំនួនមួយដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្តក្នុងជំហានទី៣ សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានលក្ខណសម្បត្តិទាំងអស់ អាសនៈនោះត្រូវបែងចែកទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ។

ក្នុងករណីនៅសល់អាសនៈច្រើនជាងមួយដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តក្នុងជំហានទី៣ ហើយអាសនៈចំនួនមួយត្រូវបែងចែកទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត ។ បន្ទាប់មកត្រូវអនុវត្តតាមរូបមន្តនេះម្តងទៀតដោយបង្កើនតម្លៃ អ្ន ចំនួន ១ ចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានទទួលអាសនៈចំនួនមួយក្នុងការអនុវត្តរូបមន្តលើកទីមួយ ។ ដូច្នេះអាសនៈចំនួនមួយ ត្រូវផ្តល់ទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុតក្នុងការអនុវត្តរូបមន្តលើកទីពីរ ។ ក្នុងករណីនៅសល់អាសនៈត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែលដោយបែងចែក ម្តងមួយអាសនៈ ជាបន្តបន្ទាប់រហូតដល់អស់អាសនៈដែលនៅសល់ ។

## មាត្រា ២៤.-

អ្នកជាប់ឆ្នោតទាំងអស់ត្រូវបានស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតតាមចំនួនស្មើគ្នានឹងចំនួនអាសនៈនៃបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោត តាមការគណនាក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

ឈ្មោះអ្នកជាប់ឆ្នោតត្រូវស្រង់តាមលំដាប់លេខរៀងពីលើមកក្រោម តាមបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតនីមួយៗ ។

**មាត្រា ២៥.-**

ឃុំ សង្កាត់ណាដែលមានបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយគត់ដែលត្រូវបាន យល់ព្រមឱ្យចុះបញ្ជីឃុំ សង្កាត់នោះក៏ត្រូវធ្វើការបោះឆ្នោតដែរ ។

ឈ្មោះបេក្ខជនត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយនោះ តាម លំដាប់លេខរៀងពីលើមកក្រោមរហូតដល់គ្រប់អាសនៈនៅក្នុងក្រុមប្រឹក្សា ។

**មាត្រា ២៦.-**

ឈ្មោះបេក្ខជនណាដែលបានស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោត ក្នុងឃុំ សង្កាត់និងត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រួចហើយ បេក្ខជននោះ ត្រូវលុបឈ្មោះចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយ ។

**មាត្រា ២៧.-**

ក្នុងករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបែងចែកអាសនៈដែលបោះបង់ចោលនោះ ទៅឱ្យបញ្ជី បេក្ខជននៃគណបក្សនយោបាយផ្សេងទៀតដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សា ក្នុងអំឡុងពេល យ៉ាងយូរ ១៤ (ដប់បួន) ថ្ងៃ ដោយធ្វើប្រមាណវិធីតាមជំហានទាំងឡាយដូចខាងក្រោម ៖

**ជំហានទី ១ ៖** កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយ មួយទទួលបានមួយអាសនៈ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជី បេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានទទួលអាសនៈ ក្នុងការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ ដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្ស នយោបាយដែលបោះបង់ចោលអាសនៈ មកចែកជាមួយនឹងចំនួនអាសនៈដែលបោះបង់ចោល តាមរូបមន្តដូចខាងក្រោម ៖

$$ក'_{ត} = \frac{ស'_{ស}}{អ'_{ប}}$$

ក្នុងនោះ ៖

- $ក'_{ត}$ ៖ តាងឱ្យកូតាជាផលចែកដោយមិនគិតសំណល់ចែក
- $ស'_{ស}$ ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃ

គណបក្សនយោបាយទាំងអស់ ដែលបានទទួលអាសនៈក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលបានបោះបង់ចោលអាសនៈមួយឬច្រើន

- $អ_{ប}$ : តាងឱ្យចំនួនអាសនៈដែលបានបោះបង់ចោល ។

**ជំហានទី ២** : កំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល មកចែកនឹងកូតាដែលបានគិតក្នុងជំហានទីមួយ តាមរូបមន្តដូចខាងក្រោម :

$$អ'_{ន} = \frac{ស_{ប}}{ភ'_{គ}}$$

ក្នុងនោះ :

- $អ'_{ន}$ : តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទី៣

- $ស_{ប}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ

- $ភ'_{គ}$ : តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទី ១

បន្ទាប់ពីបានធ្វើការគណនាក្នុងជំហានទី២សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលមានអាសនៈក្នុងក្រុមប្រឹក្សា លើកលែងតែបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ក្នុងករណីគ្មានអាសនៈនៅសល់ដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង ។

ក្នុងករណីគណនាក្នុងជំហានទី២រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ត្រូវបន្តបែងចែកអាសនៈដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តក្នុងជំហានទី៣ ។

**ជំហានទី ៣** : អាសនៈដែលនៅសល់ត្រូវបានបែងចែកដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមរូបមន្តដូចខាងក្រោម :

$$ម'_{ធ} = \frac{ស_{ប}}{អ'_{ន}+១}$$

ក្នុងនោះ :

- ម'ឌ : តាងឱ្យមធ្យមភាគខ្ពស់បំផុត

- ស'ង : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ

- អ'ឌ : តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។

វិធីសាស្ត្រដូចមានចែងក្នុងវាក្យខ័ណ្ឌទី ៧ និង ទី ៨ នៃមាត្រា ២៣ ត្រូវអនុវត្តចំពោះការគណនាក្នុងជំហានទី ៣ និងការគណនាជាបន្តបន្ទាប់ទៀត ។

មាត្រា ២៨.-

ក្នុងករណីគណនាតាមរូបមន្តដូចមានចែងក្នុងមាត្រា ២៣ និងមាត្រា ២៧ នៃច្បាប់នេះមានលទ្ធផលស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន ដែលមិនអាចកំណត់ឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយបានទទួលអាសនៈដែលត្រូវបែងចែក គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវអនុវត្តវិធីចាប់ឆ្នោត ដើម្បីកំណត់យកបញ្ជីបេក្ខជននៃគណបក្សនយោបាយឈ្នះឆ្នោត ។

វិធីចាប់ឆ្នោតត្រូវដំណើរការតាមនីតិវិធីដែលកំណត់ដោយបទបញ្ជារបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ជំពូកទី ៥
## ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

មាត្រា ២៩.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបង្កើតការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតចំនួនមួយឬច្រើនក្នុងឃុំ សង្កាត់នីមួយៗ ។

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនីមួយៗត្រូវបម្រើឱ្យតំបន់មួយដែលបានកំណត់ ។

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនិងតំបន់ដែលការិយាល័យនោះបម្រើត្រូវស្ថិតនៅក្នុងព្រំប្រទល់ឃុំ សង្កាត់របស់ខ្លួន ។

មាត្រា ៣០.-

ការរៀបចំការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតត្រូវគោរពតាមល័ក្ខខ័ណ្ឌនៃច្បាប់នេះ និងល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ៤៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតមួយត្រូវធ្វើការចុះឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតយ៉ាងច្រើន ៦០០(ប្រាំមួយរយ)នាក់ លើកលែងតែមានការសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប៉ុន្តែការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនត្រូវឱ្យមានអ្នកចុះឈ្មោះបោះឆ្នោតលើសពី ៧០០(ប្រាំពីររយ) នាក់ឡើយ ។

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតត្រូវផ្អែកទៅលើការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតដែលបានបង្កើតឡើងសម្រាប់ការបោះឆ្នោតចុងក្រោយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសិទ្ធិធ្វើការកែសម្រួលការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត និងតំបន់ដែលការិយាល័យនេះបម្រើបាន ក្នុងករណីមានការប្រែប្រួលប្រជាសាស្ត្រ និងភូមិសាស្ត្រ ។

ការកែសម្រួលការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ត្រូវធ្វើឡើងយ៉ាងតិច ១៥(ដប់ប្រាំ)ថ្ងៃមុនកាលបរិច្ឆេទនៃការចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងចុះឈ្មោះអ្នកបោះឆ្នោត ។

មាត្រា ៣១.-

ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតទាំងអស់នឹងក្លាយទៅជាការិយាល័យបោះឆ្នោតនៅពេលបោះឆ្នោត និងជាការិយាល័យរាប់សន្លឹកឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាសាធារណៈ នូវឈ្មោះទីតាំងនៃការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនីមួយៗ នៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត និងនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ក្នុងរយៈពេល ១០(ដប់)ថ្ងៃយ៉ាងតិចមុនកាលបរិច្ឆេទនៃការចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងការចុះឈ្មោះអ្នកបោះឆ្នោត។

មាត្រា ៣២.-

ជនគ្រប់រូបមានសិទ្ធិស្នើសុំពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនូវបញ្ជីឈ្មោះអ្នកបោះឆ្នោត និងទីតាំងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតផ្លូវការមួយ ឬច្រើននៅក្នុងឃុំ សង្កាត់ ដោយបង់ថ្លៃត្រឹមតម្លៃផលិត ។

មាត្រា ៣៣.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបង្កើតតាមបទបញ្ជានិងនីតិវិធី នូវការិយាល័យបោះឆ្នោតមួយឬច្រើនសម្រាប់ឃុំ សង្កាត់នីមួយៗ ។

ការិយាល័យបោះឆ្នោតនីមួយៗនិងតំបន់ដែលការិយាល័យនេះបម្រើ ត្រូវដូចគ្នានឹងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ដែលបានបង្កើតឡើងស្របតាមមាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់នេះ ។

មាត្រា ៣៤.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិជ្រើសយកបរិវេណឬអាគារតែមួយធ្វើជាការិយាល័យបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតពីរ ឬច្រើន ប្រសិនបើមិនធ្វើឱ្យប៉ះពាល់ដល់ប្រក្រតីភាពនៃការគ្រប់គ្រងនិងការប្រព្រឹត្តទៅនៃការបោះឆ្នោត ។

ការិយាល័យបោះឆ្នោតជាច្រើនដែលតាំងនៅបរិវេណឬអាគារតែមួយនោះ ត្រូវរៀបចំឱ្យស្ថិតនៅដាច់ដោយឡែកពីគ្នា ។

ការិយាល័យបោះឆ្នោតនីមួយៗដែលតាំងនៅបរិវេណឬអាគារតែមួយនោះ ត្រូវគ្រប់គ្រងឱ្យដាច់ចេញពីគ្នានិងខុសពីការិយាល័យបោះឆ្នោតផ្សេងទៀត ទៅតាមបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៣៥.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាសាធារណៈ នូវឈ្មោះនិងទីតាំងនៃការិយាល័យបោះឆ្នោតនីមួយៗ នៅការិយាល័យបោះឆ្នោតនិងនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ចាប់តាំងពីកាលបរិច្ឆេទនៃការចុះបញ្ជីបេក្ខជនរហូតដល់ពេលបិទការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ។

មាត្រា ៣៦.-

ការរាប់សន្លឹកឆ្នោតត្រូវធ្វើឡើងនៅនឹងការិយាល័យបោះឆ្នោត ។

ការិយាល័យបោះឆ្នោតជាការិយាល័យរាប់សន្លឹកឆ្នោត ។

ការិយាល័យរាប់សន្លឹកឆ្នោតជាកន្លែងរាប់សន្លឹកឆ្នោត និងជាកន្លែងប្រកាសលទ្ធផលបណ្ដោះអាសន្ននៃការរាប់សន្លឹកឆ្នោត ។

មាត្រា ៣៧.-

គ្រប់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត គ្រប់ការិយាល័យបោះឆ្នោតនិងគ្រប់ការិយាល័យរាប់សន្លឹកឆ្នោតត្រូវមានបរិវេណខាងក្នុងដែលដៅសម្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បរិវេណខាងក្នុងជាតំបន់ដែលនៅជុំវិញការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោត ខ័ណ្ឌដោយរង្វង់មណ្ឌលមួយដែលមានកាំប្រវែងយ៉ាងតិច ១៥(ដប់ប្រាំ) ម៉ែត្រ ។

បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចេញមួយនិងច្រកចូលមួយ ។

មាត្រា ៣៨.-

គ្រប់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត គ្រប់ការិយាល័យបោះឆ្នោតនិងគ្រប់ការិយាល័យរាប់សន្លឹកឆ្នោតត្រូវមានបរិវេណខាងក្រៅ ដែលដៅសម្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បរិវេណខាងក្រៅ ជាតំបន់ដែលនៅជុំវិញការិយាល័យទាំងនោះ ខ័ណ្ឌដោយរង្វង់មណ្ឌលមួយដែលមានកាំប្រវែង ១០០(មួយរយ)ម៉ែត្រឬមានទម្រង់ផ្សេងឬមានកាំតូចជាង ស្របទៅតាមស្ថានភាពជាក់ស្ដែងនៃបរិវេណខាងក្រៅរបស់ការិយាល័យនីមួយៗនោះ ។

មាត្រា ៣៩.-

ហាមយកអាវុធ ជាតិផ្ទុះ ឬសារជាតិនិងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុងនិងក្នុងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ការិយាល័យបោះឆ្នោតព្រមទាំងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងក្នុងករណីដែលមានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុងនិងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យ

បោះឆ្នោត ការិយាល័យរាប់សន្លឹកឆ្នោត ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនិងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់មានភារកិច្ចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ស្របតាមលក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ ។

មាត្រា ៤០.-

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនិងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម :

- មន្ត្រីចុះឈ្មោះដែលបានទទួលការចាត់តាំងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អ្នកសង្កេតការណ៍មានប័ណ្ណសម្គាល់ដែលផ្តល់ឱ្យដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ភ្នាក់ងារនៃគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយហើយដែលបានអនុញ្ញាត
- ប្រជាពលរដ្ឋដែលមានបំណងចុះឈ្មោះហើយដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតនៅឡើយ
- ជនអមដំណើរអ្នកសុំចុះឈ្មោះដែលជាជនពិការស្របតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៥៩ នៃច្បាប់នេះ
- ជនដែលអមដំណើរអ្នកសុំចុះឈ្មោះក្នុងគោលបំណងធ្វើការធានាដល់អ្នកសុំចុះឈ្មោះតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៥៤ នៃច្បាប់នេះ
- ភ្នាក់ងារសន្តិសុខនិងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធានការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតសំណូមពរក្នុងករណីចាំបាច់ ។

ហាមជនគ្រប់រូបចូលក្នុងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត មុនពេលការិយាល័យចាប់ផ្តើមធ្វើការ ឬក្រោយពេលការិយាល័យបិទទ្វារ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៤១.-

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោតនិងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម :

- មន្ត្រីបោះឆ្នោតដែលបានទទួលការចាត់តាំងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- ភ្នាក់ងារនៃគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះនិងដែលបានអនុញ្ញាត និងអ្នកសង្កេតការណ៍ដែលមានប័ណ្ណសម្គាល់ផ្តល់ជូនដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- អ្នកដែលមានសិទ្ធិបោះឆ្នោតហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ

- ជនដែលអមដំណើរអ្នកបោះឆ្នោតជាជនពិការតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១៧៨ នៃច្បាប់នេះ

- ភ្នាក់ងារសន្តិសុខនិងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធានការិយាល័យបោះឆ្នោតធ្វើសំណូមពរក្នុងករណីចាំបាច់ ។

ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោតមុនចាប់ផ្តើមការបោះឆ្នោតឬក្រោយបិទការបោះឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៤២.-

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោតនិងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម :

- មន្ត្រីរាប់សន្លឹកឆ្នោតដែលបានទទួលការចាត់តាំងពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- ភ្នាក់ងារនៃគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ និងដែលបានអនុញ្ញាត និងអ្នកសង្កេតការណ៍ដែលមានប័ណ្ណសម្គាល់ផ្តល់ឱ្យដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- ភ្នាក់ងារសន្តិសុខនិងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធានការិយាល័យរាប់សន្លឹកឆ្នោតធ្វើសំណូមពរក្នុងករណីចាំបាច់ ។

ហាមជនគ្រប់រូបចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត មុនពេលចាប់ផ្តើមការរាប់សន្លឹកឆ្នោត ឬក្រោយការរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៤៣.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ប្រធានការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ប្រធានការិយាល័យបោះឆ្នោត ប្រធានការិយាល័យរាប់សន្លឹកឆ្នោត ត្រូវចាត់វិធានការចាំបាច់ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ការិយាល័យបោះឆ្នោតនិងការិយាល័យរាប់សន្លឹកឆ្នោត និងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការវិវាទអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងរក្សាការពារឧបករណ៍សម្ភារៈទាំងអស់ក្នុងការិយាល័យទាំងនោះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ប្រធានការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ប្រធានការិយាល័យបោះឆ្នោតនិងប្រធានការិយាល័យរាប់សន្លឹកឆ្នោតអាចអនុវត្តនូវល័ក្ខខ័ណ្ឌនៃមាត្រា ៤០ ៤១ និងមាត្រា ៤២ នៃច្បាប់នេះ ចំពោះបរិវេណខាងក្រៅទាំងមូល ឬមួយផ្នែកក្នុងករណីចាំបាច់ដើម្បីធានាឱ្យការចុះឈ្មោះអ្នកបោះឆ្នោត ការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព ។

មាត្រា ៤៤.-

សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់នៅក្នុងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតបរិវេណខាងក្នុង និងបរិវេណខាងក្រៅ :

- ការស្លៀកពាក់ឬការបិទផ្សាយ ឬការនិយាយដែលមានការពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ
- ការបង្ហាញការគាំទ្រ ឬការប្រឆាំងចំពោះគណបក្សនយោបាយណាមួយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ
- ការវិវាទអុកឡុក ឬសកម្មភាពផ្សេងៗ ដែលអាចមានឥទ្ធិពលដល់ជនណាម្នាក់ក្នុងការចុះឈ្មោះបោះឆ្នោត ។

មាត្រា ៤៥.-

សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុងនិងបរិវេណខាងក្រៅ :

- ការស្មៀកពាក់ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ

- ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមនុស្សម្នាក់បោះឆ្នោតឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ

- ការបង្ហាញការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

មាត្រា ៤៦.-

សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុងនិងបរិវេណខាងក្រៅ :

- ការស្មៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ

- ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីរាប់សន្លឹកឆ្នោត រាប់គំនូសនៅលើសន្លឹកឆ្នោតដើម្បីបំពេញចិត្ត ឬប្រឆាំងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

មាត្រា ៤៧.-

ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ការិយាល័យបោះឆ្នោត ការិយាល័យរាប់សន្លឹកឆ្នោតនិងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រងនិងការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតស្របតាមលក្ខខ័ណ្ឌនៃច្បាប់នេះ ។

## ជំពូកទី ៦

## បញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា ៤៨.-

ឃុំ សង្កាត់នីមួយៗត្រូវមានបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៤៩.-

បញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំឱ្យបានយ៉ាងតិចកៅសិប (៩០) ថ្ងៃមុនថ្ងៃបោះឆ្នោត ។

នាយករដ្ឋមន្ត្រីកំណត់កាលបរិច្ឆេទសម្រាប់ការចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត និងចុះឈ្មោះអ្នកបោះឆ្នោត តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងចុះឈ្មោះអ្នកបោះឆ្នោត សម្រាប់ឃុំ សង្កាត់នីមួយៗ មិនត្រូវតិចជាង ១៥(ដប់ប្រាំ)ថ្ងៃឡើយដោយគិតទាំងថ្ងៃសៅរ៍និងថ្ងៃអាទិត្យផង ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់រយៈពេលសម្រាប់ការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត និងចុះឈ្មោះអ្នកបោះឆ្នោតសម្រាប់ឃុំ សង្កាត់នានា និងកំណត់ប្រតិទិនសម្រាប់ពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត និងចុះឈ្មោះអ្នកបោះឆ្នោតតាមការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតចំពោះឃុំ សង្កាត់នីមួយៗនោះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ និងប្រតិទិននេះដល់ឃុំ សង្កាត់ទាំងអស់ ក្នុងរយៈពេលយ៉ាងតិច ៣(បី)ថ្ងៃ មុនចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងចុះឈ្មោះអ្នកបោះឆ្នោត ។

មាត្រា ៥០.-

បញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើបច្ចុប្បន្នភាពលើបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ តាមការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ។

មាត្រា ៥១.-

ក្នុងការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានភារកិច្ចទទួលខុសត្រូវ :

- ពិនិត្យអំពីបច្ចុប្បន្នភាពលើបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ
- ចុះឈ្មោះជនទាំងឡាយដែលមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត
- លុបឈ្មោះជនទាំងឡាយដែលបាត់បង់សិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត

- រៀបចំបញ្ជីឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅគ្រប់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ។

មាត្រា ៥២.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណងចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវទៅបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនរស់នៅ ។

ប្រជាពលរដ្ឋខ្មែរម្នាក់ៗត្រូវមានឈ្មោះតែមួយ នៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់ ។

មាត្រា ៥៣.-

ពេលបង្ហាញខ្លួនដើម្បីចុះឈ្មោះនៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវ :

- បង្ហាញអត្តសញ្ញាណរបស់ខ្លួនដល់មន្ត្រីចុះឈ្មោះបោះឆ្នោត
- មានសិទ្ធិចុះឈ្មោះស្របតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១៩ នៃច្បាប់នេះ
- បញ្ជាក់ថាខ្លួនមិនទាន់បានចុះឈ្មោះនៅការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយនៅឡើយ ។

មាត្រា ៥៤.-

ដើម្បីបញ្ជាក់នូវអត្តសញ្ញាណរបស់ខ្លួន ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារ ឬសំអាងណាមួយដូចខាងក្រោម :

- លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- អត្តសញ្ញាណប័ណ្ណដែលផ្តល់ឱ្យដោយរដ្ឋាភិបាលកម្ពុជា ដោយមានបិទរូបថតជាសម្គាល់
- ប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត ។

អ្នកសុំចុះឈ្មោះបោះឆ្នោតអាចកំណត់អត្តសញ្ញាណរបស់ខ្លួនបាន ដោយការធានាអះអាងរបស់អ្នកមានសិទ្ធិបោះឆ្នោតពីររូបក្នុងឃុំ សង្កាត់នោះ ធ្វើឡើងនៅចំពោះមុខមន្ត្រីចុះឈ្មោះបោះឆ្នោតដោយបញ្ជាក់ថា អ្នកសុំចុះឈ្មោះនោះ ពិតជាមនុស្សដូចដែលសាមីខ្លួនបានបញ្ជាក់អះអាងមែន ។

មាត្រា ៥៥.-

ដើម្បីបញ្ជាក់ថាខ្លួនជាប្រជាពលរដ្ឋខ្មែរ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយក្នុងចំណោមឯកសារដូចខាងក្រោម :

- លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរដែលបានផ្តល់ឱ្យអនុលោមទៅតាមអនុក្រឹត្យលេខ ៣៦ អនក្រ ចុះថ្ងៃទី ២៦ កក្កដា ឆ្នាំ ១៩៩៦
- អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល ឬកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ភស្តុតាងដែលបង្ហាញថា ឈ្មោះរបស់អ្នកសុំចុះឈ្មោះមាននៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ
- ប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត
- សំបុត្រកំណើតដែលមានបញ្ជាក់ពីសញ្ជាតិខ្មែរ
- លិខិតបញ្ជាក់ថាជាប្រជាពលរដ្ឋខ្មែរដែលផ្តល់ឱ្យដោយរាជរដ្ឋាភិបាលកម្ពុជា
- លិខិតបញ្ជាក់ ឯកសារ ឬដីការបស់តុលាការដែលបញ្ជាក់ថាឪពុក ឬម្តាយរបស់អ្នកសុំចុះឈ្មោះជាប្រជាពលរដ្ឋខ្មែរ និងឯកសារដែលបង្ហាញថាអ្នកសុំចុះឈ្មោះគឺជាកូនរបស់ឪពុក ឬម្តាយនោះ
- ឯកសារជាផ្លូវការបង្ហាញថាអ្នកសុំចុះឈ្មោះកើតនៅក្នុងប្រទេសកម្ពុជា ហើយឪពុកនិងម្តាយបរទេសរបស់ជននោះក៏កើតនិងរស់នៅស្របច្បាប់ក្នុងប្រទេសកម្ពុជាដែរ និងឯកសារជាផ្លូវការដែលបង្ហាញថាអ្នកសុំចុះឈ្មោះគឺជាកូនរបស់ឪពុកនិងម្តាយនោះ ។

មាត្រា ៥៦.-

ដើម្បីបញ្ជាក់ថាខ្លួនមានអាយុយ៉ាងតិច ១៨ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារ ឬសំអាងណាមួយដូចខាងក្រោមនេះ ៖

- ឯកសារណាមួយដូចមានចែងក្នុងមាត្រា ៥៤ និងមាត្រា ៥៥ នៃច្បាប់នេះ ដែលមានបញ្ជាក់ពីអាយុ ឬថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកសុំចុះឈ្មោះ ឬសេចក្តីធានាអះអាងរបស់អ្នកមានសិទ្ធិបោះឆ្នោតពីររូបក្នុងឃុំ សង្កាត់នោះ ធ្វើឡើងនៅចំពោះមុខមេឃុំ ចៅសង្កាត់ដោយបញ្ជាក់ថាអ្នកសុំចុះឈ្មោះនោះពិតជាមានអាយុ ១៨ឆ្នាំយ៉ាងតិច គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ប្រាកដមែន ។

មាត្រា ៥៧.-

ដើម្បីបញ្ជាក់ថាខ្លួនពិតជាមានលំនៅ នៅក្នុងឃុំ សង្កាត់ ប្រជាពលរដ្ឋត្រូវបង្ហាញឯកសារណាមួយដូចខាងក្រោម ៖

- ឯកសារទាំងឡាយដូចមានចែងក្នុងមាត្រា ៥៤ ៥៥ និងមាត្រា ៥៦ នៃច្បាប់នេះហើយដែលបញ្ជាក់ថាអ្នកសុំចុះឈ្មោះពិតជាមានលំនៅ នៅក្នុងឃុំ សង្កាត់នោះប្រាកដមែន

- លិខិតបញ្ជាក់ពីអាជ្ញាធរឃុំ សង្កាត់ថាសាមីខ្លួនពិតជាមានលំនៅ នៅក្នុងឃុំ សង្កាត់នោះប្រាកដមែន ។

មាត្រា ៥៨.-

ប្រជាពលរដ្ឋខ្មែរដែលមានលំនៅច្រើនជាងមួយកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវជ្រើសរើសយកកន្លែងតែមួយគត់ ដើម្បីចុះឈ្មោះជាអ្នកបោះឆ្នោត ។

មាត្រា ៥៩.-

អ្នកចុះឈ្មោះបោះឆ្នោតដែលជាជនពិការមិនអាចចុះឈ្មោះដោយខ្លួនឯងបាន មានសិទ្ធិជ្រើសរើសអ្នកជំនួយម្នាក់ជានីតិជនទៅជាមួយ ឬមានសិទ្ធិសុំជំនួយពីប្រធានការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ។

មាត្រា ៦០.-

ដើម្បីធ្វើបច្ចុប្បន្នភាពលើបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ សម្រាប់រៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋដែលធ្លាប់បានចុះឈ្មោះចុងក្រោយនោះ ត្រូវទៅបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះដែលខ្លួនបានចុះឈ្មោះបោះឆ្នោតចុងក្រោយ ដោយភ្ជាប់ជាមួយនូវប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតដែលផ្តល់ជូនដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងឯកសារ ឬសំអាងដូចមានចែងក្នុងមាត្រា ៥៧ នៃច្បាប់នេះ ។

ផ្អែកលើបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ ដែលផ្តល់ជូនដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មន្ត្រីចុះឈ្មោះបោះឆ្នោតត្រូវ :

- ពិនិត្យប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ដើម្បីបញ្ជាក់ថាប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតនោះពិតជារបស់សាមីជនអ្នកសុំចុះឈ្មោះបោះឆ្នោតដែលផ្តល់ជូនដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយនៅរក្សារូបភាពទ្រង់ទ្រាយអាចប្រើប្រាស់បាន

- ពិនិត្យលេខប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើតរបស់សាមីខ្លួនអ្នកសុំចុះឈ្មោះក្នុងប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត ហើយផ្ទៀងផ្ទាត់ជាមួយលេខប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត នាមត្រកូលនិងនាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយនៃការិយាល័យនោះ

- ពិនិត្យអត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា ៥៧ នៃច្បាប់នេះដើម្បីបញ្ជាក់ថា អ្នកសុំចុះឈ្មោះពិតជាមានលំនៅនៅក្នុងឃុំ សង្កាត់ដែលខ្លួនកំពុងចុះឈ្មោះប្រាកដមែន ។

មាត្រា ៦១.-

ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបំពេញបានតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៦០ នៃច្បាប់នេះ មន្ត្រីចុះឈ្មោះត្រូវ :

- ផ្តល់ដំណឹងដល់អ្នកសុំចុះឈ្មោះបោះឆ្នោតថាការសុំចុះឈ្មោះនោះត្រូវបានយល់ព្រម

- ចុះឈ្មោះអ្នកសុំចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌកំណត់

- ផ្តល់ដំណឹងដល់អ្នកសុំចុះឈ្មោះបោះឆ្នោតថាប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតនោះនឹងត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

- ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះជូនអ្នកសុំចុះឈ្មោះបោះឆ្នោត ។

មាត្រា ៦២.-

ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតចុងក្រោយ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅការិយាល័យដែលកំពុងសុំចុះឈ្មោះនោះប្រាកដមែន ប៉ុន្តែប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតរបស់សាមីខ្លួនត្រូវបាត់ ឬខូចមិនអាចប្រើប្រាស់បាន មន្ត្រីចុះឈ្មោះបោះឆ្នោតត្រូវ :

- ផ្តល់ដំណឹងដល់អ្នកសុំចុះឈ្មោះបោះឆ្នោតឱ្យបំពេញបែបបទស្តីពីការបាត់ ឬខូចប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតទៅតាមបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- ពិនិត្យអត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះដូចមានចែងក្នុងមាត្រា ៥៤ និងមាត្រា ៥៧ នៃច្បាប់នេះ ។

ផ្អែកតាមអត្តសញ្ញាណខាងលើនេះ មន្ត្រីចុះឈ្មោះបោះឆ្នោតត្រូវពិនិត្យនិងរកឱ្យឃើញនូវលេខប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយនៃការិយាល័យចុះឈ្មោះបោះឆ្នោតនោះ ដើម្បីបំពេញបែបបទដូចមានចែងក្នុងមាត្រា ៦៣ នៃច្បាប់នេះ ។

មាត្រា ៦៣.-

ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបំពេញបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៦២ នៃច្បាប់នេះ មន្ត្រីចុះឈ្មោះបោះឆ្នោតត្រូវ :

- ផ្តល់ដំណឹងដល់អ្នកសុំចុះឈ្មោះបោះឆ្នោតថា ការសុំចុះឈ្មោះនោះត្រូវបានយល់ព្រម

- ចុះឈ្មោះអ្នកសុំចុះឈ្មោះបោះឆ្នោតនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុម

ប្រឹក្សាឃុំ សង្កាត់ តាមលក្ខខ័ណ្ឌដែលបានកំណត់

- ចេញវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត ដោយមានបិទរូបថតរបស់សាមីខ្លួនតាមគំរូដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយផ្ដល់ដំណឹងដល់អ្នកសុំចុះឈ្មោះបោះឆ្នោតថា វិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតនេះ នឹងត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

- ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះជូនអ្នកសុំចុះឈ្មោះបោះឆ្នោត ។

## មាត្រា ៦៤.-

ប្រជាពលរដ្ឋដែលធ្លាប់បានចុះឈ្មោះបោះឆ្នោតចុងក្រោយនៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៃឃុំ សង្កាត់ណាមួយ ហើយសាមីជននៅមានប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត ប៉ុន្តែបច្ចុប្បន្នសាមីខ្លួនឈប់រស់នៅក្នុងឃុំ សង្កាត់នោះតទៅទៀត ឈ្មោះប្រជាពលរដ្ឋនោះនឹងត្រូវបានលុបចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតចុងក្រោយនោះ ។

ប្រជាពលរដ្ឋខាងលើនេះត្រូវទៅបង្ហាញខ្លួន និងចុះឈ្មោះនៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតណាមួយនៃឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅ ។

មន្ត្រីចុះឈ្មោះបោះឆ្នោតត្រូវ :

- ពិនិត្យប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតដើម្បីបញ្ជាក់ថា ប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតនោះពិតជារបស់សាមីជនអ្នកសុំចុះឈ្មោះបោះឆ្នោត ដែលបានផ្តល់ជូនដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រាកដមែន

- ពិនិត្យអត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា ៥៧ នៃច្បាប់នេះ ដើម្បីបញ្ជាក់ថាសាមីជនអ្នកសុំចុះឈ្មោះបោះឆ្នោតពិតជាប្រជាពលរដ្ឋដែលមានទីលំនៅនៅក្នុងឃុំ សង្កាត់នោះប្រាកដមែន ។

## មាត្រា ៦៥.-

ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបំពេញបានត្រឹមត្រូវតាមលក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៦៤ នៃច្បាប់នេះ មន្ត្រីចុះឈ្មោះបោះឆ្នោតត្រូវ :

- ផ្តល់ដំណឹងដល់អ្នកសុំចុះឈ្មោះបោះឆ្នោតថា ការសុំចុះឈ្មោះនោះត្រូវបានទទួលយល់ព្រម

- ដកហូតប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតពីសាមីជនអ្នកសុំចុះឈ្មោះបោះឆ្នោត

- ចេញប័ណ្ណបោះឆ្នោតទៅតាមគំរូដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជូនសាមីជនអ្នកសុំចុះឈ្មោះបោះឆ្នោត

- ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះជូនអ្នកសុំចុះឈ្មោះបោះឆ្នោត ។

មាត្រា ៦៦.-

ដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋដែលអះអាងថាធ្លាប់បានចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៃឃុំ សង្កាត់ណាមួយ ប៉ុន្តែប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតរបស់ខ្លួនត្រូវបាត់ ឬខូចមិនអាចប្រើប្រាស់បាន ហើយបច្ចុប្បន្នសាមីខ្លួនឈប់រស់នៅក្នុងឃុំ សង្កាត់នោះតទៅទៀត និងប្រជាពលរដ្ឋដែលមានអាយុ ១៨ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងប្រជាពលរដ្ឋដែលពុំបានចុះឈ្មោះបោះឆ្នោតពីមុនមក ត្រូវបំពេញនូវល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៥២ ៥៣ ៥៤ ៥៥ ៥៦ ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានបំពេញត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៥២ ៥៣ ៥៤ ៥៥ ៥៦ ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ មន្ត្រីចុះឈ្មោះបោះឆ្នោតត្រូវ :

- ផ្តល់ដំណឹងដល់អ្នកចុះឈ្មោះបោះឆ្នោតថា ការសុំចុះឈ្មោះនោះត្រូវបានទទួលយល់ព្រម

- ចុះឈ្មោះអ្នកសុំចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌកំណត់

- ចេញប័ណ្ណបោះឆ្នោតទៅតាមគំរូដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជូនអ្នកសុំចុះឈ្មោះបោះឆ្នោត

- ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះជូនអ្នកសុំចុះឈ្មោះបោះឆ្នោត ។

មាត្រា ៦៧.-

មិនត្រូវចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ ចំពោះជនណាមួយដែលមិនបានបំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៥២ ៥៣ ៥៤ ៥៥ ៥៦ ៥៧ ៥៨ ៦០ ៦២ ៦៤ និងមាត្រា ៦៦ នៃច្បាប់នេះ ។

ក្នុងករណីខាងលើនេះ មន្ត្រីចុះឈ្មោះបោះឆ្នោតត្រូវ :

- បំពេញទម្រង់បែបបទបដិសេធ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើទម្រង់បែបបទនោះ ហើយផ្តល់សេចក្តីចម្លងមួយច្បាប់ដល់អ្នកសុំចុះឈ្មោះបោះឆ្នោត

- ផ្តល់ដំណឹងដល់អ្នកសុំចុះឈ្មោះបោះឆ្នោតថាសាមីខ្លួនឬតំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរអំពីការបដិសេធនោះទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ

- ផ្តល់ទម្រង់បែបបទប្តឹងតវ៉ាដល់អ្នកសុំចុះឈ្មោះបោះឆ្នោតឬតំណាងសម្រាប់ប្តឹង

- ផ្ញើទម្រង់បែបបទបដិសេធមួយច្បាប់ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ដើម្បីជ្រាបនិងរក្សាទុកជាឯកសារ ។

មាត្រា ៦៨.-

អ្នកសុំចុះឈ្មោះបោះឆ្នោតដែលត្រូវបានបដិសេធមិនឱ្យចុះឈ្មោះ ដោយមន្ត្រីចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតណាមួយ សាមីជន ឬតំណាងមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត តាមទម្រង់បែបបទដែលកំណត់ក្នុងរយៈពេលយ៉ាងយូរប្រាំ (៥)ថ្ងៃ ។

មាត្រា ៦៩.-

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទប្តឹងតវ៉ា ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវកាលបរិច្ឆេទ ពេលវេលានិងទីកន្លែងដែលនឹងត្រូវបើកសវនាការនេះ ។

## មាត្រា ៧០.-

ក្នុងករណីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតបានសម្រេចយល់ព្រមតាមការប្ដឹងតវ៉ា គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចារយល់ព្រម និងចុះហត្ថលេខាលើទម្រង់បែបបទប្ដឹងតវ៉ា ហើយប្រគល់មួយច្បាប់ជូនអ្នកប្ដឹងតវ៉ានិងរក្សាទុកជាឯកសារមួយច្បាប់។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវ :

- ចុះឈ្មោះអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតតាមល័ក្ខខ័ណ្ឌកំណត់
- ចេញប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតមានបិទរូបថតជូនអ្នកសុំចុះឈ្មោះ
- ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះជូនអ្នកសុំចុះឈ្មោះ
- ផ្ញើឯកសារពាក់ព័ន្ធនិងការយល់ព្រមចុះឈ្មោះអ្នកបោះឆ្នោត ជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតមួយច្បាប់និងរក្សាទុកជាឯកសារមួយច្បាប់ ។

## មាត្រា ៧១.-

ក្នុងករណីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតបដិសេធលើការប្ដឹងតវ៉ា គណៈ-កម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវ :

- បំពេញទម្រង់បែបបទបដិសេធដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ រួចចុះហត្ថលេខានិងកាលបរិច្ឆេទ ជូនអ្នកសុំចុះឈ្មោះបោះឆ្នោតមួយច្បាប់ ជូនគណៈ-កម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់
- ផ្ដល់ទម្រង់បែបបទប្ដឹងតវ៉ាតាមការកំណត់ដល់អ្នកសុំចុះឈ្មោះបោះឆ្នោត ឬតំណាងសម្រាប់ប្ដឹងតវ៉ា
- អ្នកសុំចុះឈ្មោះបោះឆ្នោត ឬតំណាងមានសិទ្ធិប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរជំទាស់នឹងការបដិសេធនេះទៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទបដិសេធ ។

## មាត្រា ៧២.-

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទប្ដឹងតវ៉ា ។

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវកាលបរិច្ឆេទ ពេលវេលានិងទីកន្លែងដែលនឹងត្រូវបើកសវនាការខាងលើនេះ ។

សេចក្តីសម្រេចរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតជាសេចក្តីសម្រេចចុងក្រោយ ។

មាត្រា ៧៣.-

ក្នុងករណីគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតបានសម្រេចយល់ព្រមតាមការប្តឹងតវ៉ា គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវចារយល់ព្រម និងចុះហត្ថលេខាលើទម្រង់បែបបទប្តឹងតវ៉ាហើយប្រគល់ជូនអ្នកប្តឹងតវ៉ាមួយច្បាប់ ចម្លងជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតមួយច្បាប់និងទុកជាឯកសារមួយច្បាប់ ។

មាត្រា ៧៤.-

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវ :

- ចារយល់ព្រម និងចុះហត្ថលេខាលើទំរង់បែបបទប្តឹងតវ៉ា រួចប្រគល់ជូនអ្នកប្តឹងតវ៉ាមួយច្បាប់
- ចុះឈ្មោះអ្នកសុំចុះឈ្មោះបោះឆ្នោតនោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតតាមល័ក្ខខ័ណ្ឌកំណត់
- ចេញប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតមានបិទរូបថតជូនអ្នកសុំចុះឈ្មោះបោះឆ្នោត
- ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះជូនអ្នកសុំចុះឈ្មោះ
- ផ្ញើឯកសារពាក់ព័ន្ធនឹងការយល់ព្រមចុះឈ្មោះអ្នកបោះឆ្នោត ជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតមួយច្បាប់និងរក្សាទុកជាឯកសារមួយច្បាប់ ។

មាត្រា ៧៥.-

ក្នុងករណីគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតបដិសេធការប្តឹងតវ៉ា គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវ :

- បំពេញទម្រង់បែបបទបដិសេធដែលបានកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការ

បដិសេធឱ្យបានច្បាស់លាស់ ចុះហត្ថលេខានិងកាលបរិច្ឆេទ ហើយចម្លងជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតដែលពាក់ព័ន្ធមួយច្បាប់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មួយច្បាប់និងរក្សាទុកជាឯកសារមួយច្បាប់

- ចារបដិសេធនិងចុះហត្ថលេខាលើទម្រង់បែបបទប្តឹងតវ៉ា រួចជូនដល់អ្នកប្តឹងមួយច្បាប់

- ផ្តល់ដំណឹងដល់អ្នកប្តឹងតវ៉ាថា សេចក្តីសម្រេចរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតជាសេចក្តីសម្រេចចុងក្រោយ ។

**មាត្រា ៧៦.-**

បន្ទាប់ពីបញ្ចប់រយៈពេលនៃការចុះឈ្មោះអ្នកបោះឆ្នោត ហើយការប្តឹងតវ៉ាទាំងអស់ក៏ត្រូវបានដោះស្រាយរួចរាល់ជាស្ថាពរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់កាលបរិច្ឆេទនិងរយៈពេលសម្រាប់ការបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះអ្នកបោះឆ្នោតដំបូង នៅតាមការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់និងនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

ជនគ្រប់រូបមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតទាក់ទងទៅនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោតដំបូងនេះ ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីរយៈពេលបិទផ្សាយជាសាធារណៈ ។

**មាត្រា ៧៧.-**

ពាក្យប្តឹងតវ៉ាអាចធ្វើឡើងអំពីការបាត់ឈ្មោះជនណាម្នាក់ពីក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតប៉ុន្តែកត់ត្រាមិនច្បាស់លាស់ ទៅតាមករណីដូចខាងក្រោម :

- ជននោះបានសុំចុះឈ្មោះនៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតណាមួយរួចហើយ ឬមានប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត ឬទម្រង់បែបបទ ឬឯកសារដែលបានផ្តល់ជូនក្នុងពេល ឬបន្ទាប់ពីពេលចុះឈ្មោះដែលផ្តល់សិទ្ធិឱ្យជននោះអាចចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតបាន ប៉ុន្តែជននោះគ្មានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត

- មានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ប៉ុន្តែកត់ត្រាមិនច្បាស់លាស់ ។

អ្នកប្តឹងតវ៉ាត្រូវបង្ហាញភស្តុតាងជាឯកសារណាមួយដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

មាត្រា ៧៨.-

ពាក្យបណ្តឹងជំទាស់ចំពោះជនណាម្នាក់ដែលគ្មានសិទ្ធិចុះឈ្មោះបោះឆ្នោតអាចធ្វើបាន លុះត្រាតែជននោះបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតណាមួយរួចហើយ ឬគ្មានសិទ្ធិចុះឈ្មោះបោះឆ្នោតតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់នេះ ប៉ុន្តែជននោះមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតណាមួយ ឬបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតចំនួនពីរ ឬច្រើន ។

អ្នកប្តឹងជំទាស់ត្រូវផ្តល់ពត៌មានបន្ថែមដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតតាមសេចក្តីស្នើសុំ ។

មាត្រា ៧៩.-

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបិទផ្សាយជាសាធារណៈ នៅទីស្នាក់ការរបស់ខ្លួននូវ :

- ឈ្មោះនិងអាសយដ្ឋានរបស់អ្នកប្តឹងជំទាស់ ឬអ្នកប្តឹងតវ៉ា និងជនដែលត្រូវគេប្តឹងជំទាស់
- កាលបរិច្ឆេទ ពេលវេលានិងទីកន្លែងដែលត្រូវបើកសវនាការនេះ ។

មាត្រា ៨០.-

ក្នុងករណីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតយល់ព្រមតាមការប្តឹងតវ៉ា គណៈ-កម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចារយល់ព្រមនិងចុះហត្ថលេខាលើទម្រង់បែបបទប្តឹងតវ៉ា និងរក្សាទុកជាឯកសារមួយច្បាប់ រួចហើយត្រូវចុះឈ្មោះអ្នកសុំចុះឈ្មោះនោះជាបន្ទាន់ទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៧០ នៃច្បាប់នេះ ។

មាត្រា ៨១.-

ក្នុងករណីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតបដិសេធលើបណ្តឹងតវ៉ា គណៈ-កម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវអនុវត្តបែបបទនិងនីតិវិធីដូចមានចែងក្នុងមាត្រា ៧១ នៃច្បាប់នេះ ។

មាត្រា ៨២.-

ក្នុងករណីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតបដិសេធបណ្តឹងជំទាស់ណាមួយ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវ :

- បំពេញទម្រង់បែបបទបដិសេធដែលបានកំណត់ ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ចំពោះការបដិសេធលើការជំទាស់នោះ ចុះហត្ថលេខានិងកាលបរិច្ឆេទជូនដល់អ្នកប្តឹងជំទាស់មួយច្បាប់ ជូនដល់អ្នកដែលត្រូវគេប្តឹងជំទាស់មួយច្បាប់ ហើយផ្ញើទម្រង់បែបបទនេះជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតមួយច្បាប់និងរក្សាទុកជាឯកសារមួយច្បាប់

- ជូនទម្រង់បែបបទដល់អ្នកប្តឹងជំទាស់ ឬតំណាងសម្រាប់ប្តឹងតវ៉ា

- ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ថា សាមីខ្លួនឬតំណាងមានសិទ្ធិធ្វើការប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃបន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងស្តីពីការបដិសេធនោះ ។

មាត្រា ៨៣.-

ករណីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតបានសម្រេចយល់ព្រមតាមពាក្យប្តឹងជំទាស់ណាមួយ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវ :

- ចារយល់ព្រមនិងចុះហត្ថលេខាលើទម្រង់បែបបទជំទាស់ រួចហើយផ្តល់ជូនអ្នកប្តឹងជំទាស់មួយច្បាប់ ជូនជនដែលត្រូវគេប្តឹងជំទាស់មួយច្បាប់ ផ្ញើជូនគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោតមួយច្បាប់និងរក្សាទុកជាឯកសារមួយច្បាប់

- ផ្តល់ទម្រង់បែបបទប្តឹងតវ៉ាដល់ជនដែលត្រូវគេប្តឹងជំទាស់

- ផ្តល់ដំណឹងដល់អ្នកដែលត្រូវគេប្តឹងជំទាស់ថា សាមីខ្លួនឬតំណាងមានសិទ្ធិធ្វើការប្តឹង

តវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងស្ដីពីការយល់ព្រមលើបណ្ដឹងជំទាស់នោះ ក្នុងករណីជនដែលត្រូវគេប្ដឹងជំទាស់មិនបានធ្វើការប្ដឹងតវ៉ាក្នុងរយៈពេលដែលបានកំណត់ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបដិសេធការចុះឈ្មោះរបស់ជនដែលត្រូវគេប្ដឹងជំទាស់ ហើយត្រូវលុបឈ្មោះជននោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ព្រមទាំងដកហូត និងបដិសេធនូវប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតរបស់ជននោះ

- គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវផ្ញើឯកសារដែលពាក់ព័ន្ធនឹងការលុបឈ្មោះខាងលើនេះជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

### មាត្រា ៨៤.-

ការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់ដូចមានចែងក្នុងមាត្រា ៨១ ៨២ និងមាត្រា ៨៣ នៃច្បាប់នេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់បែបបទដែលកំណត់ ជូនផ្ទាល់ទៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្ដីសម្រេចរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

- សេចក្ដីសម្រេចរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតជាសេចក្ដីសម្រេចចុងក្រោយ ។

### មាត្រា ៨៥.-

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទបណ្ដឹងនោះ ។

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវ :

- ឈ្មោះនិងអាសយដ្ឋានរបស់អ្នកប្ដឹងតវ៉ាឬអ្នកប្ដឹងជំទាស់ និងជនដែលត្រូវគេប្ដឹងជំទាស់
- កាលបរិច្ឆេទ ពេលវេលានិងទីកន្លែងដែលត្រូវបើកសវនាការនោះ ។

មាត្រា ៨៦.-

ក្នុងករណីគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតយល់ព្រមតាមការប្តឹងតវ៉ារបស់ជនណាម្នាក់ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវចារយល់ព្រម និងចុះហត្ថលេខាលើទម្រង់បែបបទប្តឹងតវ៉ា ហើយជូនអ្នកប្តឹងតវ៉ាមួយច្បាប់ ចម្លងជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់និងរក្សាទុកជាឯកសារមួយច្បាប់ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចុះឈ្មោះអ្នកសុំចុះឈ្មោះបោះឆ្នោតនោះជាបន្ទាន់ទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៧៤ នៃច្បាប់នេះ។

មាត្រា ៨៧.-

ក្នុងករណីគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតបដិសេធការប្តឹងតវ៉ារបស់ជនណាម្នាក់ គណៈកម្មការត្រូវអនុវត្តនូវបែបបទនិងនីតិវិធីដូចមានចែងក្នុងមាត្រា ៧៥ នៃច្បាប់នេះ ។

មាត្រា ៨៨.-

ក្នុងករណីគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតយល់ព្រមតាមការប្តឹងជំទាស់របស់ជនណាម្នាក់ ឬបដិសេធការប្តឹងតវ៉ារបស់ជនដែលត្រូវគេប្តឹងជំទាស់ណាមួយ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវចារយល់ព្រម និងចុះហត្ថលេខាលើទម្រង់បែបបទប្តឹងជំទាស់ ឬប្តឹងតវ៉ាជូនអ្នកប្តឹងនោះមួយច្បាប់ ចម្លងជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់និងរក្សាទុកជាឯកសារមួយច្បាប់ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបដិសេធការចុះឈ្មោះជនដែលត្រូវគេប្តឹងជំទាស់ ហើយត្រូវលុបឈ្មោះជននោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ព្រមទាំងដកហូតនិងបដិសេធប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតរបស់ជននោះ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវផ្ញើឯកសារពាក់ព័ន្ធនឹងការលុបឈ្មោះជននោះជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

មាត្រា ៨៩.-

បន្ទាប់ពីការប្តឹងតវ៉ានិងការប្តឹងជំទាស់ទាំងអស់នៅក្នុងឃុំ សង្កាត់ត្រូវបានដោះស្រាយតាមលំដាប់ថ្នាក់រួចរាល់ជាស្ថាពរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

- ចុះហត្ថលេខានិងកាលបរិច្ឆេទ លើបញ្ជីឈ្មោះអ្នកបោះឆ្នោតសម្រាប់ការិយាល័យ

ចុះឈ្មោះអ្នកបោះឆ្នោតនីមួយៗបញ្ជាក់ថា បញ្ជីនេះជាបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

- ត្រួតពិនិត្យនិងរក្សាសុវត្ថិភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការនេះ ។

មាត្រា ៩០.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិលុបឈ្មោះរបស់ជនណាម្នាក់នៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត នៅពេលដែលមានភស្តុតាងបញ្ជាក់ថាជននោះមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតច្រើនកន្លែង ។

មាត្រា ៩១.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចម្លងបញ្ជីឈ្មោះអ្នកបោះឆ្នោតផ្លូវការសម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ និងបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះអ្នកបោះឆ្នោតជាផ្លូវការនេះ នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតនិងនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ទៅតាមកាលបរិច្ឆេទនិងពេលវេលាដែលបានកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ៩២.-

ជនណាដែលមានប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតរបស់អ្នកបោះឆ្នោតដែលស្លាប់ ត្រូវប្រគល់ប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតនោះដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតដើម្បីមោឃភាព ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវរៀបចំបញ្ជីមួយសម្រាប់អ្នកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលស្លាប់ ហើយត្រូវចារលើឈ្មោះជននោះថា ស្លាប់ ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវយកទៅប្រើប្រាស់ក្នុងពេលបោះឆ្នោត ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវរាយការណ៍ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមរយៈគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតអំពីឈ្មោះអ្នកដែលស្លាប់នោះ ដោយភ្ជាប់ជាមួយនូវប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតរបស់អ្នកស្លាប់នោះផង ។

មាត្រា ៩៣.-

ក្នុងការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃការិយាល័យបោះឆ្នោតនីមួយៗ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

- បញ្ចូលឈ្មោះអ្នកបោះឆ្នោតគ្រប់រូបក្នុងបញ្ជីនោះដោយដាក់អាសយដ្ឋាន អាយុ ភេទ និងលេខប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតខាងលើនេះដែលមានតែមួយគត់សម្រាប់អ្នកបោះឆ្នោតម្នាក់ៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

- បញ្ជាក់ឈ្មោះឃុំ សង្កាត់និងលេខសម្គាល់ការិយាល័យបោះឆ្នោត

- រៀបចំបញ្ជីតាមទម្រង់ដូចគ្នា

- ចុះហត្ថលេខានិងកាលបរិច្ឆេទ ។

បញ្ជីឈ្មោះអ្នកបោះឆ្នោតអាចត្រូវធ្វើការកែសម្រួលនិងដាក់បញ្ចូលគ្នាជាមួយបញ្ជីឈ្មោះអ្នកបោះឆ្នោតដទៃទៀត ដើម្បីបង្កើតបញ្ជីរួមមួយសម្រាប់ថ្នាក់ឃុំ សង្កាត់ ឬថ្នាក់ខេត្ត ក្រុង ឬថ្នាក់ជាតិស្របតាមច្បាប់កំណត់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតខាងលើនេះជារៀងរាល់ឆ្នាំ ។

## ជំពូកទី ៧

## ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា ៩៤.-

ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត

- ចេះអាននិងសរសេរអក្សរខ្មែរ

- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរ

ឈ្មោះបោះឆ្នោត

- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ៩៥.-

ហាមឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ :

- សមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិករាជរដ្ឋាភិបាល និងចៅក្រម

- ប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរងខេត្ត ក្រុង ស្រុក ខ័ណ្ឌ

- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត មន្ត្រីការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោត បុគ្គលិកបំរើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនិងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់

- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង

- ព្រះសង្ឃ ឬបព្វជិតសាសនានៃសាសនាណាមួយ

- ស្មៀនឃុំ សង្កាត់ណាមួយ ។

មាត្រា ៩៦.-

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិច ៧(ប្រាំពីរ)ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។

ប្រសិនបើសាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅសាមីក្រសួង ឬសាមីអង្គភាពទៅបម្រើការក្រៅក្របខ័ណ្ឌដើមក្នុងរយៈពេលអាណត្តិរបស់ខ្លួន ក្នុងឋានៈនេះ សាមីខ្លួនត្រូវមានសិទ្ធិឡើងថ្នាក់និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ ។

នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សាមីខ្លួនអាចសុំត្រឡប់មកបំរើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសំរេច ។

មាត្រា ៩៧.-

បន្ទាប់ពីនាយករដ្ឋមន្ត្រីកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៣ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយនៅក្នុងឃុំ សង្កាត់នីមួយៗ នូវកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កាលបរិច្ឆេទនៃការចុះបញ្ជីបេក្ខជន និងទីកន្លែង ។

មាត្រា ៩៨.-

ជនគ្រប់រូបដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ។

បញ្ជីបេក្ខជននីមួយៗត្រូវរៀបចំដោយគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវ តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ។

បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង។

មាត្រា ៩៩.-

បេក្ខជនម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយប៉ុណ្ណោះ។

មាត្រា ១០០.-

ដើម្បីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត យ៉ាងតិច ៩០(កៅសិប)ថ្ងៃមុនថ្ងៃបោះឆ្នោត ។

ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។

មាត្រា ១០១.-

ពាក្យសុំចុះបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយនូវ ៖

- សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃមួយច្បាប់

- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ អាសយដ្ឋានទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ និងឈ្មោះអ្នកតំណាងប្រចាំទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ដែលបានដាក់ស្នើបញ្ជីបេក្ខជន

- បញ្ជីរាយនាមបេក្ខជនដែលមានចំនួនបេក្ខជនយ៉ាងហោចណាស់ស្មើនឹងពីរដងនៃចំនួនសមាជិកក្រុមប្រឹក្សាក្នុងក្រុមប្រឹក្សាឃុំ សង្កាត់

- នាមត្រកូល នាមខ្លួន អាសយដ្ឋាននិងលេខប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតរបស់បេក្ខជនគ្រប់រូបនៅក្នុងបញ្ជីបេក្ខជន

- ជីវប្រវត្តិសង្ខេបដែលបំពេញផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗនិងរូបថតបេក្ខជន ម្នាក់ចំនួន ៣សន្លឹក ទំហំ ៤ x ៦ ថតចំពីមុខ តាមគំរូដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់និងសញ្ញាសម្គាល់គណបក្សនយោបាយ ។

មាត្រា ១០២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជនសម្រាប់ឃុំ សង្កាត់នីមួយៗ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទនិងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជន នៅគ្រប់ទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនមានរយៈពេល ៣(បី)ថ្ងៃ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចេញបង្កាន់ដៃទទួលពាក្យឱ្យគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន និងរក្សាគល់បញ្ជីមួយច្បាប់ទុកជាឯកសារ ។

បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួនឯកសារដែលបានទទួល ចុះកាលបរិច្ឆេទប្រគល់ទទួលនិងហត្ថលេខា ឬស្នាមមេដៃនៃអ្នកប្រគល់ទទួល ។

មាត្រា ១០៣.-

បន្ទាប់ពីថ្ងៃបញ្ចប់ការទទួលពាក្យសុំចុះបញ្ជីបេក្ខជន គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើការពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនទាំងនោះក្នុងរយៈពេល ១(មួយ)ថ្ងៃ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួន នូវបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានទទួលពាក្យសុំចុះបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរបី (៣)ថ្ងៃ បន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជន ។

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ មានសិទ្ធិផ្តល់មតិចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានបិទផ្សាយខាងលើ មកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

មាត្រា ១០៤.-

ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយដែលបានបំពេញត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៩៤ ៩៥ ៩៦ ៩៨ ៩៩ ១០០ និងមាត្រា ១០១ នៃច្បាប់នេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវសម្រេចយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជននោះ និងចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនឱ្យគណបក្សនយោបាយដែលបានដាក់ស្នើបញ្ជីបេក្ខជន ក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យសុំចុះបញ្ជីបេក្ខជន ។

មាត្រា ១០៥.-

ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយដែលបំពេញមិនបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៩៤ ៩៥ ៩៦ ៩៨ ៩៩ ១០០ និងមាត្រា ១០១ នៃច្បាប់នេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរនិងណែនាំដល់គណបក្សនយោបាយដែលបានដាក់ស្នើបញ្ជីបេក្ខជននោះ ឱ្យធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ ហើយផ្តល់ឱកាសឱ្យគណបក្សនយោបាយនោះធ្វើការកែតម្រូវចំណុចខ្វះខាតក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ។

## មាត្រា ១០៦.-

ក្នុងករណីគណបក្សនយោបាយដែលបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីចំណុចដែលស្នើឱ្យធ្វើការកែតម្រូវ បានធ្វើការកែតម្រូវចំណុចខ្វះខាតបានត្រឹមត្រូវ និងទាន់ពេលវេលា គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រូវយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជនហើយចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយនោះ ។

## មាត្រា ១០៧.-

ក្នុងករណីគណបក្សនយោបាយដែលដាក់ស្នើបញ្ជីបេក្ខជនមិនបានកែតម្រូវចំណុចខ្វះខាតតាមពេលវេលាដូចមានចែងក្នុងមាត្រា ១០៥ នៃច្បាប់នេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបដិសេធពាក្យសុំចុះបញ្ជីបេក្ខជននោះ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវ :

- បំពេញទម្រង់បែបបទបដិសេធដែលបានកំណត់ដោយបញ្ជាក់ពីមូលហេតុជាក់លាក់នៃការបដិសេធ រួចហើយចុះហត្ថលេខានិងកាលបរិច្ឆេទជូនដល់គណបក្សនយោបាយសាមី ឬតំណាងមួយច្បាប់
- ប្រគល់ទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាដល់សាមីគណបក្សនយោបាយដែលបានដាក់ស្នើបញ្ជីបេក្ខជន
- ផ្ញើទម្រង់បែបបទបដិសេធជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

## មាត្រា ១០៨.-

គណបក្សនយោបាយណាដែលបានដាក់ស្នើបញ្ជីបេក្ខជន ហើយបញ្ជីបេក្ខជននោះត្រូវបានបដិសេធដោយគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត សាមីគណបក្សនយោបាយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទបដិសេធ ។

## មាត្រា ១០៩.-

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធារណៈ ក្នុងរយៈពេលយ៉ាងយូរបី (៣)ថ្ងៃ ក្រោយពីបានទទួលទម្រង់បែបបទប្តឹងតវ៉ា ។

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបិទផ្សាយជាសាធារណៈ នៅទីស្នាក់ការរបស់ខ្លួននូវកាលបរិច្ឆេទ ពេលវេលានិងទីកន្លែងដែលត្រូវបើកសវនាការនោះ ។

មាត្រា ១១០.-

ក្នុងករណីគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតយល់ព្រមលើការប្តឹងតវ៉ា គណៈ-កម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវចារយល់ព្រម និងចុះហត្ថលេខាលើទម្រង់បែបបទប្តឹងតវ៉ាជូនដល់អ្នកប្តឹងតវ៉ាមួយច្បាប់ និងចម្លងជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះ និងត្រូវចុះបញ្ជីបេក្ខជននោះ ហើយចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយសាមី ។

មាត្រា ១១១.-

ក្នុងករណីគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតបដិសេធលើបណ្តឹងតវ៉ា គណៈ-កម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវ :

- បំពេញទម្រង់បែបបទបដិសេធតាមការកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ ចុះហត្ថលេខា និងកាលបរិច្ឆេទ
- ផ្តល់ទម្រង់បែបបទបដិសេធដែលបំពេញរួចដល់គណបក្សនយោបាយសាមីមួយច្បាប់ និងចម្លងជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់
- ប្រគល់ទម្រង់បែបបទដល់គណបក្សនយោបាយដែលដាក់ស្នើបញ្ជីបេក្ខជនសម្រាប់ប្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ផ្ញើទម្រង់បែបបទបដិសេធដែលបំពេញរួចមួយច្បាប់ ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដើម្បីជ្រាប និងរក្សាទុកជាឯកសារមួយច្បាប់ ។

មាត្រា ១១២.-

គណបក្សនយោបាយដែលបានដាក់ស្នើបញ្ជីបេក្ខជន ហើយបញ្ជីបេក្ខជននោះត្រូវបានបដិសេធដោយគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត សាមីគណបក្សនយោបាយឬ

តំណាងមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទបដិសេធ ។

មាត្រា ១១៣.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ ក្រោយពីបានទទួលទម្រង់បែបបទប្តឹងតវ៉ា ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួន នូវកាលបរិច្ឆេទ ពេលវេលានិងទីកន្លែងដែលត្រូវបើកសវនាការនេះ ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសេចក្តីសម្រេចចុងក្រោយ ។

មាត្រា ១១៤.-

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ព្រមលើការប្តឹងតវ៉ា គណៈកម្មាធិការត្រូវចារយល់ព្រមនិងចុះហត្ថលេខាលើទម្រង់បែបបទប្តឹងតវ៉ា ជូនអ្នកប្តឹងតវ៉ាមួយច្បាប់ ជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ និងទុកជាឯកសារមួយច្បាប់ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវផ្តល់ការយល់ព្រម លើពាក្យសុំចុះបញ្ជីបេក្ខជននិងត្រូវចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយនោះ ហើយចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូនដល់គណបក្សនយោបាយសាមី ។

មាត្រា ១១៥.-

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបដិសេធបណ្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

- បំពេញទម្រង់បែបបទបដិសេធ ចុះហត្ថលេខានិងកាលបរិច្ឆេទ
- ផ្តល់ទម្រង់បែបបទដែលបំពេញរួច ដល់គណបក្សនយោបាយសាមី ឬតំណាងមួយច្បាប់ ដល់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់
- ផ្តល់ដំណឹងដល់គណបក្សនយោបាយដែលដាក់ពាក្យប្តឹងតវ៉ាឬតំណាងថា សេចក្តី

សម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសេចក្តីសម្រេចចុងក្រោយ ។

មាត្រា ១១៦.-

បន្ទាប់ពីបញ្ចប់រយៈពេលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ហើយការប្តឹងតវ៉ាទាំងអស់ត្រូវបានដោះស្រាយរួចរាល់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យគណៈ-កម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួន នូវបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ ។

មាត្រា ១១៧.-

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អំពីបញ្ជីបេក្ខជនដំបូងដូចមានចែងក្នុងមាត្រា ១១៦ នៃច្បាប់នេះ ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយជាសា-ធារណៈ ។

មាត្រា ១១៨.-

បណ្តឹងជំទាស់ត្រូវចោទប្រកាន់ទៅលើបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយដែលបំពេញមិនបាន តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៩៤ ៩៥ ៩៦ ៩៨ ៩៩ ១០០ និងមាត្រា ១០១ នៃច្បាប់នេះ ។

បណ្តឹងជំទាស់ត្រូវបង្ហាញអំពីបញ្ជីបេក្ខជននៃគណបក្សនយោបាយជាក់លាក់ណាមួយដោយបញ្ជាក់ពីចំណុចខ្វះខាតជាក់ស្តែងរបស់បញ្ជីបេក្ខជននោះ និងហេតុផលដែលស្នើសុំឱ្យប្រោនចោលការចុះបញ្ជីបេក្ខជននោះ ។

មាត្រា ១១៩.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ ក្រោយពីបានទទួលបណ្តឹងជំទាស់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់ព័ត៌មានដល់គណបក្សនយោបាយដែលបានដាក់ស្នើបញ្ជីបេក្ខជនមានការប្តឹងជំទាស់ ផ្តល់ព័ត៌មានដល់អ្នកប្តឹងជំទាស់ និងផ្សព្វផ្សាយជាសាធារណៈអំពីកាលបរិច្ឆេទ ពេលវេលានិងទីកន្លែងដែលត្រូវបើកសវនាការនោះ ។

មាត្រា ១២០.-

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ព្រម ឬបដិសេធបណ្តឹងជំទាស់ណាមួយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

- បំពេញទម្រង់បែបបទតាមការកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការយល់ព្រម ឬបដិសេធលើបណ្តឹងជំទាស់នោះ រួចហើយចុះហត្ថលេខានិងកាលបរិច្ឆេទលើទម្រង់បែបបទនោះ

- ផ្តល់ទម្រង់បែបបទដែលបានបំពេញរួចដល់អ្នកប្តឹងជំទាស់មួយច្បាប់ ដល់គណបក្សនយោបាយដែលបានដាក់ស្នើបញ្ជីបេក្ខជនហើយមានការប្តឹងជំទាស់មួយច្បាប់ ដល់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់

- ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់និងសាមីគណបក្សនយោបាយនៃបញ្ជីបេក្ខជននោះថា សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសេចក្តីសម្រេចចុងក្រោយ ។

មាត្រា ១២១.-

ក្នុងករណីបណ្តឹងជំទាស់ត្រូវបានយល់ព្រម គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបដិសេធការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានការប្តឹងជំទាស់នោះ រួចហើយលុបបញ្ជីបេក្ខជននោះចេញ ព្រមទាំងដកហូតនិងបដិសេធលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជននោះ ។

មាត្រា ១២២.-

បញ្ជីបេក្ខជនដំបូងនឹងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការប្រសិនបើគ្មានបណ្តឹងជំទាស់មកលើបញ្ជីនេះ ក្នុងរយៈពេលដូចដែលបានកំណត់ក្នុងមាត្រា ១១៧ នៃច្បាប់នេះ ឬការប្តឹងជំទាស់ត្រូវបានដោះស្រាយស្របតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រា ១១៩ ១២០ និងមាត្រា ១២១ នៃច្បាប់នេះ ។

មាត្រា ១២៣.-

ផ្អែកលើបញ្ជីបេក្ខជនផ្លូវការដូចមានចែងក្នុងមាត្រា ១២២ នៃច្បាប់នេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជន

ដែលត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្ដីរាយការណ៍អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមរយៈគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត។

នីតិវិធីនៃការចាប់ឆ្នោតត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១២៤.-

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជនក្នុងបញ្ជីនីមួយៗ ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ)ថ្ងៃ ។

បញ្ជីបេក្ខជនផ្លូវការ ឈ្មោះនិងលំដាប់ឈ្មោះបេក្ខជននៅក្នុងបញ្ជីមិនអាចកែប្រែបានឡើយ ។

មាត្រា ១២៥.-

គណបក្សនយោបាយនិងបេក្ខជននៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីជាផ្លូវការ ត្រូវគោរពក្រមសីលធម៌ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ជំពូកទី ៨

## ការឃោសនាបោះឆ្នោត

មាត្រា ១២៦.-

ការឃោសនាបោះឆ្នោតមានបំណងឱ្យគណបក្សនយោបាយដែលបានអនុញ្ញាតឱ្យចុះបញ្ជីបេក្ខជន និងបេក្ខជនធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ ដល់អ្នកបោះឆ្នោត ។

មាត្រា ១២៧.-

ការឃោសនាបោះឆ្នោតមានរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាត្រូវបញ្ឈប់ ២៤(ម្ភៃបួន)ម៉ោងមុនថ្ងៃបោះឆ្នោត ។

មាត្រា ១២៨.-

ក្នុងសកម្មភាពឃោសនា គណបក្សនយោបាយ ឬបេក្ខជននីមួយៗមិនត្រូវប្រព្រឹត្តអំពើគំរាមកំហែង បំភិតបំភ័យ ឬប្រព្រឹត្តអំពើហិង្សាមកលើប្រជាពលរដ្ឋ គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រដទៃទៀត ។

គណបក្សនយោបាយ ឬបេក្ខជនមិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន គំរាមកំហែង ប្រព្រឹត្តអំពើហិង្សា ឬការបំភិតបំភ័យមកលើគណបក្សនយោបាយ បេក្ខជន ឬអ្នកបោះឆ្នោតផ្សេងទៀត ។

មាត្រា ១២៩.-

មន្ត្រីរាជការគ្រប់ផ្នែកនិងគ្រប់ថ្នាក់ ក្រសួងស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាលព្រមទាំងកងយោធពលខេមរភូមិន្ទនិងនគរបាលជាតិ ត្រូវប្រកាន់ជំហរអព្យាក្រឹត្យឥតលម្អៀង ហើយមិនត្រូវប្រើអំណាច ឬឥទ្ធិពល ឬប្រព្រឹត្តសកម្មភាពណាមួយដែលលម្អៀងទៅរកការគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។

មាត្រា ១៣០.-

អង្គការក្រៅរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគមឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវប្រកាន់ជំហរអព្យាក្រឹត្យ ឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

អង្គការក្រៅរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគមឬអង្គការអន្តរជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីដូចខាងក្រោម :

- ផ្តួចផ្តើម ឬចូលរួមនៅក្នុងការឃោសនារបស់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ
- ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយដែលគាំទ្រ ឬបង្ហាញភាពលម្អៀង ឬប្រឆាំងគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ
- ផ្តល់មធ្យោបាយជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយ ។

មាត្រា ១៣១.-

ក្នុងពេលឃោសនាបោះឆ្នោតនិងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវគោរពតាមវិធានបទប្បញ្ញត្តិនិងគោលការណ៍ដែលចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រមសីលធម៌ គោរពតាមបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គោរពតាមគោលការណ៍សិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៣២.-

កាសែត វិទ្យុនិងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ពត៌មាន ដែលស្នើឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយអំពីការប្រព្រឹត្តទៅនៃការបោះឆ្នោតនិងការចាត់ចែងអប់រំការបោះឆ្នោត ។

មាត្រា ១៣៣.-

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីធ្លាសាធារណៈ ឬសាលសាធារណៈ ត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលសុំចូលប្រើប្រាស់សម្រាប់ឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាពនិងតាមលំដាប់លំដោយ តាមកាលបរិច្ឆេទនៃការស្នើសុំ ។

គណបក្សនយោបាយ ឬបេក្ខជនដែលមានបំណងចូលរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីធ្លាសាធារណៈ ឬសាលសាធារណៈត្រូវដាក់ពាក្យសុំទៅអ្នកគ្រប់គ្រងយ៉ាងហោច ៣(បី)ថ្ងៃមុនថ្ងៃប្រជុំឃោសនា ហើយត្រូវផ្ញើសេចក្តីចម្លងនៃពាក្យសុំនេះមួយច្បាប់ដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

អ្នកគ្រប់គ្រងត្រូវឆ្លើយតបទៅនឹងពាក្យស្នើសុំមិនឱ្យលើសពី ២៤(ម្ភៃបួន)ម៉ោង ក្រោយពីបានទទួលពាក្យស្នើសុំ ។

មាត្រា ១៣៤.-

គណបក្សនយោបាយនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ឬបេក្ខជនអាចធ្វើការឃោសនាទៅតាមកន្លែងឯកជនបាន តែត្រូវមានការយល់ព្រមជាមួយម្ចាស់កន្លែងនោះ ហើយត្រូវឱ្យជំហរ៉ះ

ជាមុនទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត អំពីកាលបរិច្ឆេទនៃការឃោសនាបោះឆ្នោតនោះ ។

មាត្រា ១៣៥.-

គណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រមិនត្រូវជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពរបស់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រផ្សេងទៀត ។

មាត្រា ១៣៦.-

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនិងរបៀបរៀបរយ ក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ បញ្ជីបេក្ខជននៃគណបក្សនយោបាយនិងបេក្ខជនក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដោយស្មើភាព ។

## ជំពូកទី ៩
## ភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍

មាត្រា ១៣៧.-

ក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត និងចុះឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយ ក្នុងរយៈពេលយ៉ាងតិច ៩០(កៅសិប)ថ្ងៃ មុនថ្ងៃចាប់ផ្តើមធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងចុះឈ្មោះអ្នកបោះឆ្នោត មានសិទ្ធិចាត់តាំងភ្នាក់ងារម្នាក់និងភ្នាក់ងារបម្រុងម្នាក់ហៅថាភ្នាក់ងារនៃគណបក្សនយោបាយ នៅការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនីមួយៗ ។

ភ្នាក់ងារនៃគណបក្សនយោបាយ ត្រូវអនុញ្ញាតឱ្យចូលទៅក្នុងការិយាល័យចុះឈ្មោះតែម្នាក់ប៉ុណ្ណោះ ។

ភ្នាក់ងារបម្រុងនៃគណបក្សនយោបាយ ត្រូវអនុញ្ញាតឱ្យជំនួសភ្នាក់ងារពេញសិទ្ធិក្នុងករណីភ្នាក់ងារពេញសិទ្ធិអវត្តមាន ។

មាត្រា ១៣៨.-

គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្ដីពីគណបក្សនយោបាយ ហើយមានបំណងបញ្ជូនភ្នាក់ងាររបស់ខ្លួនចូលរួមពិនិត្យមើលដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត និងចុះឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃ មុនកាលបរិច្ឆេទនៃការចាប់ផ្ដើមពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងចុះឈ្មោះអ្នកបោះឆ្នោត ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ៤៩ នៃច្បាប់នេះ ។

ពាក្យសុំចុះឈ្មោះជាភ្នាក់ងារនៃគណបក្សនយោបាយ ត្រូវភ្ជាប់ជាមួយនូវច្បាប់ចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនោះនៅក្រសួងមហាផ្ទៃមួយច្បាប់ បញ្ជីឈ្មោះភ្នាក់ងារដែលជានីតិជន ដោយបញ្ជាក់នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋាននៃភ្នាក់ងារម្នាក់ៗ ព្រមទាំងការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតដែលភ្នាក់ងារម្នាក់ៗត្រូវបំពេញការងារ ។

មាត្រា ១៣៩.-

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចុះឈ្មោះនិងផ្ដល់ប័ណ្ណសម្គាល់ដល់ភ្នាក់ងារនៃគណបក្សនយោបាយណាដែលបំពេញបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រា ១៣៨ នៃច្បាប់នេះ ។

ក្នុងករណីភ្នាក់ងារនៃគណបក្សនយោបាយណាមួយដែលមិនបានបំពេញតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រា ១៣៨ នៃច្បាប់នេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅគណបក្សនយោបាយសាមី ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យស្នើសុំ ។

គណបក្សនយោបាយនោះមានសិទ្ធិដាក់ពាក្យស្នើសុំចុះឈ្មោះភ្នាក់ងារជាថ្មីមួយលើកទៀតជំនួសឈ្មោះភ្នាក់ងារដែលបានបដិសេធមកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធ ។

មាត្រា ១៤០.-

គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

ឃុំ សង្កាត់ មានសិទ្ធិចាត់តាំងភ្នាក់ងារម្នាក់និងភ្នាក់ងារបម្រុងម្នាក់ ហៅថាភ្នាក់ងារនៃគណបក្សនយោបាយ នៅតាមការិយាល័យបោះឆ្នោតនិងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ដែលខ្លួនឈរឈ្មោះបោះឆ្នោត ។

ភ្នាក់ងារនៃគណបក្សនយោបាយនៅតាមការិយាល័យបោះឆ្នោតនិងការិយាល័យរាប់សន្លឹកឆ្នោតមួយ ត្រូវមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយ ក្នុងឃុំ សង្កាត់នោះ ។

ភ្នាក់ងារនៃគណបក្សនយោបាយត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតែម្នាក់ប៉ុណ្ណោះ ។

ភ្នាក់ងារបម្រុងនៃគណបក្សនយោបាយត្រូវអនុញ្ញាតឱ្យជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីភ្នាក់ងារពេញសិទ្ធិអវត្តមាន ។

មាត្រា ១៤១.-

គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារនិងភ្នាក់ងារបំរុងរបស់ខ្លួនមកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជន តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១២៤ នៃច្បាប់នេះ ។

ពាក្យសុំចុះឈ្មោះជាភ្នាក់ងារនៃគណបក្សនយោបាយ ត្រូវបញ្ជាក់នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋាននិងលេខប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតរបស់ភ្នាក់ងារម្នាក់ៗ និងការិយាល័យបោះឆ្នោតដែលភ្នាក់ងារនោះត្រូវបំពេញការងារ ។

មាត្រា ១៤២.-

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចុះឈ្មោះ ហើយផ្តល់ប័ណ្ណសម្គាល់ដល់ភ្នាក់ងារនៃគណបក្សនយោបាយណាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងមាត្រា ១៤០ និងមាត្រា ១៤១ នៃច្បាប់នេះ ។

ក្នុងករណីភ្នាក់ងារនិងភ្នាក់ងារបំរុងណាម្នាក់ដែលបំពេញមិនបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១៤០ និងមាត្រា ១៤១ នៃច្បាប់នេះ គណៈកម្មការឃុំ សង្កាត់រៀបចំការ

បោះឆ្នោតត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅគណបក្សនយោបាយសាមី ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ ក្រោយពីបានទទួលពាក្យស្នើសុំ ។

គណបក្សនយោបាយមានសិទ្ធិដាក់ពាក្យស្នើសុំចុះឈ្មោះភ្នាក់ងារនិងភ្នាក់ងារបំរុងរបស់ខ្លួនជាថ្មីមួយលើកទៀត ជំនួសឈ្មោះភ្នាក់ងារនិងភ្នាក់ងារបំរុងដែលបានបដិសេធ មកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធ ។

## មាត្រា ១៤៣.-

គណបក្សនយោបាយដែលគ្មានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅឃុំ សង្កាត់ណាមួយ នៅក្នុងឃុំ សង្កាត់នោះ គណបក្សនយោបាយនោះមានសិទ្ធិបញ្ជូនសមាជិករបស់ខ្លួនជាប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យចូលរួមជាអ្នកសង្កេតការណ៍ក្នុងដំណើរការបោះឆ្នោតនិងដំណើរការរាប់សន្លឹកឆ្នោត ។

## មាត្រា ១៤៤.-

គណបក្សនយោបាយដែលគ្មានបញ្ជីបេក្ខជនឈរឈ្មោះដូចមានចែងក្នុងមាត្រា ១៤៣ នៃច្បាប់នេះ ត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជនតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១២៤ នៃច្បាប់នេះ ។

ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍នៃគណបក្សនយោបាយដែលគ្មានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជាក់នាមត្រកូល នាមខ្លួន អាស័យដ្ឋាន និងលេខប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតរបស់អ្នកសង្កេតការណ៍ម្នាក់ៗនិងការិយាល័យបោះឆ្នោត ព្រមទាំងការិយាល័យរាប់សន្លឹកឆ្នោតដែលអ្នកសង្កេតការណ៍នោះត្រូវបំពេញការងារ ។

## មាត្រា ១៤៥.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចុះឈ្មោះ ហើយផ្តល់ប័ណ្ណសម្គាល់ដល់អ្នកសង្កេតការណ៍នៃគណបក្សនយោបាយដែលគ្មានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតណាដែល

មានលក្ខណសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងមាត្រា ១៤៣ និង ១៤៤ នៃច្បាប់នេះ ។

ក្នុងករណីអ្នកសង្កេតការណ៍ណាម្នាក់ដែលបំពេញមិនបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១៤៣ និង ១៤៤ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅគណបក្សនយោបាយសាមី ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំ ។

គណបក្សនយោបាយសាមីអាចដាក់ពាក្យស្នើសុំចុះឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួនជាថ្មីមួយលើកទៀតជំនួសឈ្មោះអ្នកសង្កេតការណ៍ដែលបានបដិសេធ ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធ ។

មាត្រា ១៥៦.-

ក្នុងការចូលទៅសង្កេតការណ៍ដំណើការបោះឆ្នោតនិងដំណើរការរាប់សន្លឹកឆ្នោត អ្នកសង្កេតការណ៍នៃគណបក្សនយោបាយដែលគ្មានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត មិនត្រូវធ្វើសកម្មភាពណាមួយដូចមានចែងក្នុងមាត្រា ១៥៨ នៃច្បាប់នេះ ។

មាត្រា ១៥៧.-

សមាគមនិងអង្គការក្រៅរដ្ឋាភិបាលមានសិទ្ធិចូលរួមក្នុងឋានៈជាអ្នកសង្កេតការណ៍ក្នុងដំណើរការបោះឆ្នោតទាំងមូល ។

មាត្រា ១៥៨.-

ត្រូវបានបង្កើតឱ្យមានគណៈកម្មាធិការមួយឈ្មោះថា គណៈកម្មាធិការសម្របសម្រួលនៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាល សម្រាប់សង្កេតការណ៍បោះឆ្នោតក្នុងរយៈពេលយ៉ាងតិច ៣០(សាមសិប)ថ្ងៃ មុនកាលបរិច្ឆេទនៃការចាប់ផ្តើមពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងចុះឈ្មោះអ្នកបោះឆ្នោត ដើម្បីសម្របសម្រួលជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការរៀបចំអ្នកសង្កេតការណ៍នៃសមាគម និងអង្គការក្រៅរដ្ឋាភិបាលចូលរួមសង្កេតការណ៍ក្នុងដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត និងចុះឈ្មោះអ្នកបោះឆ្នោត ដំណើរ ការបោះឆ្នោតនិងដំណើរការរាប់សន្លឹកឆ្នោត ។

គណៈកម្មាធិការសម្របសម្រួលនៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលត្រូវបញ្ចប់អាណត្តិការងាររបស់ខ្លួន បន្ទាប់ពីប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តាមអាណត្តិនីមួយៗ ។

មាត្រា ១៤៩.-

គណៈកម្មាធិការសម្របសម្រួលនៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលសម្រាប់សង្កេតការណ៍បោះឆ្នោតរួមមាន ប្រធាន ១(មួយ)រូប អនុប្រធាន ២(ពីរ)រូបនិងសមាជិក ៤(បួន)រូប ។

ប្រធាន អនុប្រធាន សមាជិករបស់គណៈកម្មាធិការសម្របសម្រួលនៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលសម្រាប់សង្កេតការណ៍បោះឆ្នោត ត្រូវរៀបចំឡើងដោយការបោះឆ្នោតស្របតាមនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៥០.-

សមាគមនិងអង្គការក្រៅរដ្ឋាភិបាលដែលមានបំណងធ្វើជាសមាជិកក្នុងគណៈកម្មាធិការសម្របសម្រួលនៃសមាគម និងអង្គការក្រៅរដ្ឋាភិបាលសម្រាប់សង្កេតការណ៍បោះឆ្នោត ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម :

- បានចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃយ៉ាងហោចណាស់ ៩(ប្រាំបួន)ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខន្តិកៈ ឬឯកសារប្រហាក់ប្រហែលគ្នាដែលបញ្ជាក់ពីគោលបំណង ឬទិសដៅក្នុងការលើកកំពស់ការពារអភិបាលកិច្ចល្អ ប្រជាធិបតេយ្យ ឬការបោះឆ្នោត ឬសិទ្ធិមនុស្ស ឬច្បាប់ ឬយុត្តិធម៌សង្គម ។

មាត្រា ១៥១.-

សមាគមនិងអង្គការក្រៅរដ្ឋាភិបាលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងមាត្រា ១៥០ នៃច្បាប់នេះ ហើយមានបំណងធ្វើជាសមាជិកនៅក្នុងគណៈកម្មាធិការសម្របសម្រួលនៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលសម្រាប់សង្កេតការណ៍បោះឆ្នោត ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមទម្រង់បែបបទដែលកំណត់ដោយបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៥២.-

គណៈកម្មាធិការសម្របសម្រួលនៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលសម្រាប់សង្កេតការណ៍បោះឆ្នោតមានភារកិច្ច :

- សហការជាមួយសមាគមនិងអង្គការក្រៅរដ្ឋាភិបាលនានា ក្នុងការរៀបចំអ្នកសង្កេតការណ៍នៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាល ដើម្បីចូលរួមសង្កេតការណ៍ក្នុងដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ចុះឈ្មោះអ្នកបោះឆ្នោត ដំណើរការបោះឆ្នោតនិងដំណើរការរាប់សន្លឹកឆ្នោត តាមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- ហ្វឹកហ្វឺនដល់អ្នកសង្កេតការណ៍នៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលអំពីច្បាប់ និងនីតិវិធីទាក់ទងដល់ការបោះឆ្នោត

- ស្វះស្វែងរកធនធានហិរញ្ញវត្ថុ សម្ភារៈ ដើម្បីធានាឱ្យមានមធ្យោបាយគ្រប់គ្រាន់សម្រាប់បំរើដល់ដំណើរការសង្កេតការណ៍បោះឆ្នោត

- សហការជួយដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ធ្វើការអប់រំដល់អ្នកបោះឆ្នោតអំពីគោលបំណងនៃការបោះឆ្នោត និងនីតិវិធីនានាទាក់ទងដល់ដំណើរការបោះឆ្នោតទាំងមូល

- សហការជួយដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងការស្វះស្វែងរកជំនួយឧបត្ថម្ភជាមធ្យោបាយ សម្ភារៈ ថវិកា សម្រាប់បំរើការបោះឆ្នោត ។

មធ្យោបាយ ថវិកាដើម្បីសកម្មភាពរបស់គណៈកម្មាធិការសម្របសម្រួលនៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលសម្រាប់សង្កេតការណ៍បោះឆ្នោតមិនមែនជាបន្ទុកនៃថវិការដ្ឋឡើយ ។

មាត្រា ១៥៣.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសម្រេចផ្លាស់ប្តូរសមាជិកណាម្នាក់ពីគណៈកម្មាធិការសម្របសម្រួលនៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលសម្រាប់សង្កេតការណ៍បោះឆ្នោតក្នុងករណីដែលសមាជិកនោះរំលោភបំពានទៅលើច្បាប់នេះ ឬបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៥៤.-

បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលនៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលសម្រាប់សង្កេតការណ៍បោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់តាមបទបញ្ជានិងនីតិវិធីនូវ :

- ចំនួនអ្នកសង្កេតការណ៍នៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលសម្រាប់ការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ
- លក្ខណសម្បត្តិរបស់អ្នកសង្កេតការណ៍នៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាល ។

មាត្រា ១៥៥.-

គណៈកម្មាធិការសម្របសម្រួលនៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលសម្រាប់សង្កេតការណ៍បោះឆ្នោត ត្រូវរៀបចំបញ្ជីសុំចុះឈ្មោះជាអ្នកសង្កេតការណ៍នៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាល ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទៅតាមពេលវេលានិងនីតិវិធីដែលកំណត់ដោយបទបញ្ជារបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៥៦.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចុះឈ្មោះនិងផ្តល់ប័ណ្ណសម្គាល់ឱ្យអ្នកសង្កេតការណ៍ណាដែលមានលក្ខណសម្បត្តិត្រឹមត្រូវតាមការកំណត់ ដូចមានចែងក្នុងបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីអ្នកសង្កេតការណ៍ណាម្នាក់ដែលគ្មានលក្ខណសម្បត្តិគ្រប់គ្រាន់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរ ឱ្យទៅគណៈ-កម្មាធិការសម្របសម្រួលនៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលសម្រាប់សង្កេតការណ៍បោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំ ។

គណៈកម្មាធិការសម្របសម្រួលនៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលសម្រាប់សង្កេតការណ៍បោះឆ្នោត មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍នៃសមាគមនិងអង្គការក្រៅរដ្ឋាភិបាលជាថ្មីម្តងទៀត ជំនួសឈ្មោះអ្នកសង្កេតការណ៍ដែលបានបដិសេធ ឱ្យមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធ ។

មាត្រា ១៥៧.-

ភ្នាក់ងារនៃគណបក្សនយោបាយនីមួយៗមានសិទ្ធិមានវត្តមាន នៅតាមការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោតដែលខ្លួនបានទទួលការអនុញ្ញាតពីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

ភ្នាក់ងារនៃគណបក្សនយោបាយមានសិទ្ធិប្ដឹងជំទាស់រាល់ការរំលោភទៅលើច្បាប់នេះឬលើបទបញ្ជា និងនីតិវិធីដែលភ្នាក់ងារនោះបានឃើញផ្ទាល់ ។

ការជំទាស់ត្រូវធ្វើឡើងទៅប្រធានការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ប្រធានការិយាល័យបោះឆ្នោត ឬប្រធានការិយាល័យរាប់សន្លឹកឆ្នោត នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ។

ការជំទាស់ត្រូវធ្វើទៅតាមទម្រង់បែបបទដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៥៨.-

ភ្នាក់ងារនៃគណបក្សនយោបាយមិនត្រូវ :

- ផ្ដល់ការណែនាំ ឬស្ដីបន្ទោសដល់មន្ត្រីចុះឈ្មោះបោះឆ្នោត មន្ត្រីបោះឆ្នោតនិងមន្ត្រីរាប់សន្លឹកឆ្នោត
- រំខាន ឬជ្រៀតជ្រែកដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត ដំណើរការបោះឆ្នោតនិងដំណើរការរាប់សន្លឹកឆ្នោត
- លើកការប្ដឹងជំទាស់ ឬដាក់ពាក្យបណ្ដឹងជំទាស់ទៅជនណាម្នាក់ក្រៅពីប្រធានការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ប្រធានការិយាល័យបោះឆ្នោត ឬប្រធានការិយាល័យរាប់សន្លឹកឆ្នោតបានឡើយ
- រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៥៩.-

អ្នកសង្កេតការណ៍មិនត្រូវ :

- ផ្ដល់ការណែនាំ ឬស្ដីបន្ទោសដល់មន្ត្រីចុះឈ្មោះបោះឆ្នោត ឬមន្ត្រីបោះឆ្នោត ឬមន្ត្រី

រាប់សន្លឹកឆ្នោត

- រំខាន ឬជ្រៀតជ្រែកដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោត ការចុះឈ្មោះអ្នកបោះឆ្នោត ដំណើរការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោត

- រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៦០.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការផ្សព្វផ្សាយដល់គណបក្សនយោបាយ សមាគម និងអង្គការក្រៅរដ្ឋាភិបាលដែលទទួលសង្កេតការណ៍បោះឆ្នោត អំពីការគ្រប់គ្រងនិងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បទប្បញ្ញត្តិសំខាន់ៗនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងបទបញ្ជានិងនីតិវិធីរបស់ខ្លួន ។

មាត្រា ១៦១.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវអញ្ជើញតំណាងអង្គការក្រៅរដ្ឋាភិបាលបរទេស តំណាងប្រទេសនានានិងតំណាងអង្គការអន្តរជាតិឱ្យចូលរួមសង្កេតការណ៍ការបោះឆ្នោត ។

មាត្រា ១៦២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចតាក់តែងបទបញ្ជាសម្រាប់ភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ជំពូកទី ១០
## ការរៀបចំ ការគ្រប់គ្រងនិងការប្រព្រឹត្តទៅនៃការបោះឆ្នោត

មាត្រា ១៦៣.-

ឃុំ សង្កាត់នីមួយៗត្រូវមានសន្លឹកឆ្នោតដោយឡែករបស់ខ្លួន ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្តល់ជូន ។

### មាត្រា ១៦៤.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធានាបោះពុម្ពសន្លឹកឆ្នោតគ្រប់ចំនួន សម្រាប់ឃុំ សង្កាត់នីមួយៗនៅលើក្រដាស់ពណ៌ស ។

### មាត្រា ១៦៥.-

សន្លឹកឆ្នោតនីមួយៗត្រូវមានគល់បញ្ជីសន្លឹកឆ្នោត ។

លេខរៀងតាមលំដាប់តគ្នានៃសន្លឹកឆ្នោតត្រូវបោះនៅលើគល់បញ្ជីសន្លឹកឆ្នោត ។

### មាត្រា ១៦៦.-

សន្លឹកឆ្នោតនីមួយៗ ត្រូវមានសញ្ញាសម្គាល់គណបក្សនយោបាយនិងឈ្មោះគណបក្សនយោបាយជាអក្សរពេញនិងអក្សរកាត់ ។

សញ្ញាសម្គាល់គណបក្សនយោបាយនិងឈ្មោះគណបក្សនយោបាយជាអក្សរពេញនិងអក្សរកាត់ដែលត្រូវដាក់នៅលើសន្លឹកឆ្នោត ត្រូវដាក់តាមលំដាប់លំដោយ ផ្អែកតាមលទ្ធផលនៃការចាប់ឆ្នោតដូចមានចែងក្នុងមាត្រា ១២៣ នៃច្បាប់នេះ ។

### មាត្រា ១៦៧.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាផ្តល់ហិបឆ្នោតឱ្យបានគ្រប់ចំនួនសម្រាប់ឃុំ សង្កាត់នីមួយៗ ។

គ្រប់ហិបឆ្នោតទាំងអស់ត្រូវ :

- មានគម្របជាប់មកជាមួយ
- ធានានូវសុវត្ថិភាពដែលមិនអាចហូតយកសន្លឹកឆ្នោតចេញពីក្នុងហិបបាន ប្រសិនបើមិនបើកគម្រប
- មានសោ ឬឧបករណ៍ផ្សេងទៀតសម្រាប់កិបពេលបិទហិបឆ្នោត
- មានផ្លាកលេខ ឬសញ្ញាសម្គាល់នៅផ្នែកខាងក្រៅយ៉ាងច្បាស់ដែលមិនអាចដូរ ឬលុបបានដោយងាយ ហើយផ្លាកលេខ ឬសញ្ញាសម្គាល់នេះ ត្រូវមានតែមួយគត់សម្រាប់ហិបនោះ និងសម្គាល់បានថា ហិបនោះទាក់ទងទៅនឹងឃុំ សង្កាត់និងការិយាល័យបោះឆ្នោតណាមួយ ។

**មាត្រា ១៦៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធានាឱ្យមានត្រាសម្ងាត់ជាផ្លូវការគ្រប់ចំនួន និងខុសៗគ្នាសម្រាប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ ។

ការិយាល័យបោះឆ្នោតមួយត្រូវមានត្រាសម្ងាត់ជាផ្លូវការមួយ សម្រាប់បោះនៅលើផ្នែកខាងខ្នងនៃសន្លឹកឆ្នោតនីមួយៗ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតាក់តែងបទបញ្ជានិងនីតិវិធីសម្រាប់ការប្រគល់ ទទួលនិងការប្រគល់ត្រឡប់មកវិញ និងធានាឱ្យបាននូវភាពសម្ងាត់នៃត្រានេះ ។

**មាត្រា ១៦៩.-**

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវប្រគល់សម្ភារៈបោះឆ្នោតដែលចាំបាច់សម្រាប់បំរើការបោះឆ្នោតទៅឱ្យការិយាល័យបោះឆ្នោត មិនឱ្យហួសពី ៣៦(សាមសិបប្រាំមួយ) ម៉ោងមុនថ្ងៃបោះឆ្នោត ។

ការិយាល័យបោះឆ្នោតត្រូវត្រួតពិនិត្យ និងចុះហត្ថលេខាលើបង្កាន់ដៃទទួលសម្ភារៈបោះឆ្នោតទាំងអស់ដែលបានប្រគល់ឱ្យ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតាក់តែងបទបញ្ជាកំណត់អំពីសម្ភារៈបោះឆ្នោត និងនីតិវិធីសម្រាប់ការប្រគល់ ទទួលនិងការប្រគល់ត្រឡប់មកវិញនូវសម្ភារៈបោះឆ្នោត និងធានាឱ្យបាននូវភាពសម្ងាត់និងសន្តិសុខនៃសន្លឹកឆ្នោត ។

**មាត្រា ១៧០.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធានាឱ្យការិយាល័យបោះឆ្នោតនីមួយៗមានសម្ភារៈឧបករណ៍ចាំបាច់ដូចខាងក្រោម :

- តុនិងកៅអីសម្រាប់មន្ត្រីបោះឆ្នោត
- បញ្ជីឈ្មោះអ្នកបោះឆ្នោត
- សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់
- ទឹកខ្មៅជ្រលក់ដៃ
- បន្ទប់គូសសន្លឹកឆ្នោត

- ហិបឆ្នោត
- សម្ភារៈបរិក្ខារចាំបាច់ផ្សេងៗទៀត ។

មាត្រា ១៧១.-

មុនថ្ងៃបោះឆ្នោត ២៤(ម្ភៃបួន)ម៉ោង ប្រធានការិយាល័យបោះឆ្នោតត្រូវប្រជុំមន្ត្រីទាំងអស់ដើម្បីពិនិត្យវត្តមាន និងពិនិត្យទីតាំងការិយាល័យបោះឆ្នោត និងពិនិត្យសម្ភារៈបរិក្ខារបំរើឱ្យការបោះឆ្នោត ។

ក្នុងករណីបើមានមន្ត្រីណាម្នាក់អវត្តមាន មន្ត្រីនោះត្រូវជំនួសដោយមន្ត្រីថ្មីដែលជ្រើសតាំងឡើងស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងបទបញ្ជានិងនីតិវិធី ។

ប្រធានការិយាល័យបោះឆ្នោតត្រូវចាត់ការដើម្បីឱ្យការិយាល័យបោះឆ្នោតមានសម្ភារៈបរិក្ខារនិងសង្ហារឹមចាំបាច់សម្រាប់ការបោះឆ្នោត ។

ប្រធានការិយាល័យបោះឆ្នោតត្រូវពិនិត្យស្ថានភាពសន្តិសុខនៅការិយាល័យបោះឆ្នោត ហើយចាត់វិធានការការពារសន្តិសុខបើចាំបាច់ ។

មាត្រា ១៧២.-

នៅថ្ងៃបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោតគ្រប់រូបដែលបានទទួលការតែងតាំងឱ្យបំពេញការងារតាមការិយាល័យបោះឆ្នោត ត្រូវមានវត្តមានក្នុងការិយាល័យនៅម៉ោង ៦:០០ នាទី ដោយនាំមកជាមួយនូវសម្ភារៈបរិក្ខារបោះឆ្នោតទាំងអស់ ។

ចំពោះភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោតនៅម៉ោង ៦:០០ នាទី ។

មាត្រា ១៧៣.-

នៅចន្លោះពីម៉ោង ៦:០០ នាទីដល់ម៉ោង ៦:៣០ នាទី នៅថ្ងៃបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោតត្រូវរៀបចំកិច្ចការដូចខាងក្រោម :

- ពិនិត្យឡើងវិញនូវហិបឆ្នោតដែលបានផ្តល់ឱ្យនិងពិនិត្យផ្លាកលេខ ឬសញ្ញាសម្គាល់ហិបឆ្នោតឱ្យបានត្រឹមត្រូវ
- បង្ហាញអ្នកនៅក្នុងការិយាល័យបោះឆ្នោតថា ហិបឆ្នោតនីមួយៗពុំមានអ្វីក្នុងនោះឡើយ
- បិទពម្របក្តងនៃហិបឆ្នោតហើយចាក់សោឃុំ

- បិទផ្លាកលេខ ឬសញ្ញាសម្គាល់ជាប់នឹងហិបឆ្នោត ដោយមានបោះត្រារបស់ការិយាល័យបោះឆ្នោតពីលើ

- អនុញ្ញាតឱ្យភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោត ផ្លាកលេខ ឬសញ្ញាសម្គាល់ផ្សេងៗដែលបិទលើហិបឆ្នោត ។

ក្នុងករណីសម្ភារៈ ឧបករណ៍បោះឆ្នោតត្រូវបានប្រគល់ឱ្យការិយាល័យបោះឆ្នោតក្រោយម៉ោង ៦:៣០ នាទី ពេលទទួល ប្រធានការិយាល័យបោះឆ្នោតត្រូវអនុវត្តតាមនីតិវិធីខាងលើ ករណីនេះប្រធានការិយាល័យបោះឆ្នោតអាចល្អូវការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះជាបណ្តោះអាសន្នសិន រហូតដល់ពេលដែលនីតិវិធីខាងលើបានបំពេញរួចរាល់ ។

បន្ទាប់ពីបានបិទផ្លាកលេខ ឬសញ្ញាសម្គាល់លើហិបឆ្នោតរួចហើយ ហិបឆ្នោតទាំងនេះមិនអាចបើកចំហឡើយ លើកលែងតែក្នុងបំណងរាប់សន្លឹកឆ្នោតដូចមានចែងនៅក្នុងច្បាប់នេះ និងមិនអាចយកចេញពីការិយាល័យបោះឆ្នោត លើកលែងតែការដឹកជញ្ជូនទៅកន្លែងរាប់សន្លឹកឆ្នោត ក្នុងករណីដែលច្បាប់ ឬបទបញ្ជាតម្រូវឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ។

## មាត្រា ១៧៤.-

នៅចន្លោះពីម៉ោង ៦:៣០នាទីដល់ម៉ោង ៧:០០នាទី ប្រធានការិយាល័យបោះឆ្នោតត្រូវបាត់ឱ្យបើកស្រោមសំបុត្រដែលមានត្រាសម្ងាត់សម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោត រាប់សន្លឹកឆ្នោតនិងកត់ត្រាចំនួន ព្រមទាំងលេខរៀងនៅលើគល់បញ្ជីសន្លឹកឆ្នោត តាមបែបបទដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## មាត្រា ១៧៥.-

ប្រធានការិយាល័យបោះឆ្នោតត្រូវបើកការិយាល័យបោះឆ្នោតនៅម៉ោង ៧:០០នាទី

## មាត្រា ១៧៦.-

អ្នកដែលមានសិទ្ធិចូលទៅក្នុងបរិវេណខាងក្នុងនិងក្នុងការិយាល័យបោះឆ្នោតបាន លុះត្រាតែជននោះមានប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតសម្រាប់ការិយាល័យនោះ ហើយជននោះមិនទាន់បានបោះឆ្នោតនៅឡើយ ។

ជនណាដែលមិនបង្ហាញប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតដែលមាន

សុពលភាពសម្រាប់ការិយាល័យបោះឆ្នោតរបស់ខ្លួន ជននោះមិនត្រូវអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោតបានឡើយ ។

អ្នកបោះឆ្នោតម្នាក់ៗត្រូវបានផ្តល់សន្លឹកឆ្នោតឱ្យក្នុងការិយាល័យបោះឆ្នោត ក្នុងករណីដែលអ្នកបោះឆ្នោតនោះបំពេញបានតាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

- មានប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតត្រឹមត្រូវ

- មានឈ្មោះនិងលេខប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោត សម្រាប់ការិយាល័យបោះឆ្នោតនោះ

- មិនទាន់បានបោះឆ្នោតនៅឡើយ ហើយអនុញ្ញាតឱ្យមន្ត្រីបោះឆ្នោតពិនិត្យមើលម្រាមដៃរបស់បុគ្គលនោះ ។

អ្នកបោះឆ្នោតម្នាក់ៗត្រូវគូសនៅលើសន្លឹកឆ្នោតតែម្នាក់ឯង នៅក្នុងបន្ទប់គូសសន្លឹកឆ្នោតដោយឡែក ហើយដាក់សន្លឹកឆ្នោតដែលបានគូសរួចនោះចូលទៅក្នុងហិបឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកត្រូវអនុញ្ញាតឱ្យមន្ត្រីការិយាល័យបោះឆ្នោតជ្រលក់ទឹកខ្មៅលុបមិនជ្រះទៅតាមនីតិវិធីដែលបានកំណត់ ។

របៀបគូសសន្លឹកឆ្នោតនិងដាក់សន្លឹកឆ្នោតចូលក្នុងហិបឆ្នោតត្រូវកំណត់ដោយបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតាក់តែងបទបញ្ជាដើម្បីអនុវត្តជាក់ស្តែងនូវមាត្រានេះ និងកំណត់អំពីការគ្រប់គ្រងនីតិវិធីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ។

### មាត្រា ១៧៧.-

អ្នកបោះឆ្នោតដែលបានធ្វើឱ្យខូចសន្លឹកឆ្នោតដោយអចេតនា ត្រូវប្រគល់សន្លឹកឆ្នោតនេះឱ្យមន្ត្រីការិយាល័យបោះឆ្នោត ហើយមន្ត្រីការិយាល័យបោះឆ្នោតត្រូវប្រគល់សន្លឹកឆ្នោតថ្មីមួយជំនួសវិញ ទៅតាមនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

### មាត្រា ១៧៨.-

អ្នកបោះឆ្នោតដែលពិការមិនអាចបោះឆ្នោតដោយខ្លួនឯងបាន មានសិទ្ធិជ្រើសរើសអ្នកជំនួយម្នាក់ជានីតិជនទៅជាមួយ ឬមានសិទ្ធិស្នើសុំជំនួយពីប្រធានការិយាល័យបោះឆ្នោត ។

មាត្រា ១៧៩.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតាក់តែងបទបញ្ជាសម្រាប់ការពារសិទ្ធិរបស់អ្នកបោះឆ្នោតដែលពិការរាងកាយ ហើយមិនអាចជ្រលក់ទឹកខ្មៅលុបមិនជ្រះបាន ។

មាត្រា ១៨០.-

មិនអនុញ្ញាតឱ្យជនណាម្នាក់ចូលទៅជ្រៀតជ្រែក ឬជួយអ្នកបោះឆ្នោតក្នុងពេលដែលអ្នកបោះឆ្នោតស្ថិតនៅក្នុងបរិវេណខាងក្នុង ឬក្នុងការិយាល័យបោះឆ្នោតបានឡើយ លើកលែង តែមានការអនុញ្ញាតអនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ១៨១.-

មន្ត្រីការិយាល័យបោះឆ្នោត ឬភ្នាក់ងារនៃគណបក្សនយោបាយ មានសិទ្ធិប្ដឹងជំទាស់ចំពោះជនណាម្នាក់នៅក្នុងការិយាល័យបោះឆ្នោត ក្នុងករណីដែលជននោះមិនបានបំពេញតាមល័ក្ខខ័ណ្ឌណាមួយ ដូចមានចែងក្នុងមាត្រា ១៧៦ នៃច្បាប់នេះ ។

ការប្ដឹងជំទាស់ត្រូវធ្វើទៅកាន់ប្រធានការិយាល័យបោះឆ្នោត ។

ក្នុងករណីប្រធានការិយាល័យបោះឆ្នោតពិនិត្យឃើញថា ជននោះមិនបានបំពេញតាមល័ក្ខខ័ណ្ឌណាមួយដូចមានចែងក្នុងមាត្រា ១៧៦ នៃច្បាប់នេះ ជននោះមិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ ហើយជននោះត្រូវអមដំណើរដោយមន្ត្រីការិយាល័យបោះឆ្នោតឱ្យចេញក្រៅពីការិយាល័យបោះឆ្នោតនិងពីបរិវេណខាងក្នុង ។

ក្នុងករណីប្រធានការិយាល័យបោះឆ្នោតសម្រេចថា ជននោះបានបំពេញល័ក្ខខ័ណ្ឌតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៧៦ នៃច្បាប់នេះ ជននោះត្រូវបានអនុញ្ញាតឱ្យបោះឆ្នោត ។

សេចក្ដីសម្រេចរបស់ប្រធានការិយាល័យបោះឆ្នោតជាសេចក្ដីសម្រេចចុងក្រោយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់ដោយបទបញ្ជានូវ របៀបរបបប្ដឹងជំទាស់ ការដោះស្រាយនិងការកត់ត្រាអំពីករណីខាងលើនេះ ។

# ជំពូកទី ១១

## ការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោតនិងការប្រមូល ប្រគល់ ទទួលសម្ភារៈបោះឆ្នោត

**មាត្រា ១៨២.-**

ប្រធានការិយាល័យបោះឆ្នោតត្រូវប្រកាសបិទការបោះឆ្នោតនៅម៉ោង ១៥:០០នាទី ។

ជនគ្រប់រូបដែលមានបំណងបោះឆ្នោតមិនត្រូវអនុញ្ញាតឱ្យចូលទៅក្នុងបរិវេណខាងក្នុង ក្រោយម៉ោង ១៥:០០ នាទីបានឡើយ ។

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយម៉ោង ១៥:០០នាទី ហើយអាចអនុញ្ញាតឱ្យបោះឆ្នោត គឺជាជនដែលស្ថិតក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៅម៉ោង ១៥:០០ នាទី ។

**មាត្រា ១៨៣.-**

បន្ទាប់ពីប្រកាសបិទការបោះឆ្នោត និងក្រោយពីអ្នកបោះឆ្នោតគ្រប់រូបបានបោះឆ្នោត ហើយភ្លាម នៅចំពោះមុខភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ ប្រធានការិយាល័យបោះឆ្នោតត្រូវ :

- បិទប្រឡោះសម្រាប់បោះឆ្នោតគ្រប់ហិបឆ្នោតទាំងអស់ ដោយមានចុះហត្ថលេខារបស់ប្រធានការិយាល័យបោះឆ្នោតនិងភ្នាក់ងារនៃគណបក្សនយោបាយលើក្រដាសបិទប្រឡោះសម្រាប់បោះឆ្នោតនោះ រួចហើយបិទគម្របខាងក្រៅពីលើនិងចាក់សោ ហើយអនុញ្ញាតឱ្យភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោតទាំងនោះ
- ចុះក្នុងកំណត់ហេតុនូវអ្នកដែលបានមកបោះឆ្នោត
- បំពេញនិងចុះហត្ថលេខាលើទម្រង់បែបបទដោយបង្ហាញពីចំនួនសន្លឹកឆ្នោតបានទទួលដែលបានផ្តល់ឱ្យអ្នកបោះឆ្នោត សន្លឹកឆ្នោតដែលខូច ឬដែលបានដកហូតនៅក្នុងការិយាល័យបោះឆ្នោត
- បំបែកគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ ចេញពីគល់បញ្ជីសន្លឹកឆ្នោតដែលមិនបានប្រើប្រាស់ ។

បង្ហាញទម្រង់បែបបទខាងលើដែលបានបំពេញនិងចុះហត្ថលេខា រួចហើយជូនភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ដើម្បីពិនិត្យ ។

ភ្នាក់ងារនៃគណបក្សនយោបាយត្រូវចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើកំណត់ហេតុខាងលើនេះ ។

មាត្រា ១៨៤.-

សន្លឹកឆ្នោតត្រូវរាប់នៅការិយាល័យបោះឆ្នោតនីមួយៗ ក្នុងឃុំ សង្កាត់ ។

ចំពោះការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបាន ដោយករណីប្រធានសក្តិ ឬអសន្តិសុខ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនឹងធ្វើការណែនាំដោយឡែក ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំនិងគ្រប់គ្រងការិយាល័យរាប់សន្លឹកឆ្នោត ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ។

មាត្រា ១៨៥.-

មន្ត្រីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ ជាអ្នកទទួលខុសត្រូវក្នុងការរាប់សន្លឹកឆ្នោតក្នុងការិយាល័យរបស់ខ្លួន ក្នុងករណីនេះ ការិយាល័យបោះឆ្នោតនឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត ។

ក្នុងករណីសន្លឹកឆ្នោតត្រូវរាប់នៅកន្លែងផ្សេងក្រៅពីការិយាល័យបោះឆ្នោត តាមលំកូខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៨៤ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យមន្ត្រីការិយាល័យបោះឆ្នោតនោះរាប់សន្លឹកឆ្នោត ឬអាចតែងតាំងមន្ត្រីផ្សេងទៀតឱ្យរាប់សន្លឹកឆ្នោត ក្នុងករណីដែលមន្ត្រីការិយាល័យបោះឆ្នោតនោះអវត្តមាន ។

មាត្រា ១៨៦.-

ជនគ្រប់រូបនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោតនិងនៅក្នុងបរិវេណខាងក្នុង ត្រូវស្ថិតក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យរបស់ប្រធានការិយាល័យរាប់សន្លឹកឆ្នោត តាមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៨៧.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឱ្យមានឧបករណ៍ចាំបាច់មួយចំនួនក្នុងការិយាល័យរាប់សន្លឹកឆ្នោតមាន តុនិងកៅអីគ្រប់គ្រាន់សម្រាប់មន្ត្រីរាប់សន្លឹកឆ្នោត ។

ការរាប់សន្លឹកឆ្នោតត្រូវធ្វើតែមួយកន្លែងសំរាប់ការិយាល័យបោះឆ្នោតមួយ ។

ភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មមដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការរាប់សន្លឹកឆ្នោត ។

មាត្រា ១៨៨.-

បន្ទាប់ពីបំពេញបែបបទតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១៨៣ ១៨៤ និងមាត្រា ១៨៥ នៃច្បាប់នេះ ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវចាត់ឱ្យបើកហិបឆ្នោតនិងចាក់សន្លឹកឆ្នោតទាំងអស់ចេញពីក្នុងហិបឆ្នោតនីមួយៗ រួចហើយត្រូវ :

- ដាក់វត្ថុដែលមិនមែនជាសន្លឹកឆ្នោតដាច់ដោយឡែក ប្រសិនបើមាន

- លាសន្លឹកឆ្នោតដែលមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង ដោយដាក់ផ្កាប់ចុះក្រោមនៅពំនូកទី ១

- ក្នុងករណីមានសន្លឹកឆ្នោតដែលបានបោះ តែមិនមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង ត្រូវដាក់ដោយឡែកនៅពំនូកទី ២

- រាប់ចំនួនសន្លឹកឆ្នោតដែលផ្កាប់ចុះក្រោមទាំងពីរពំនូក ហើយកត់ត្រានិងបង្ហាញអំពីចំនួនសន្លឹកឆ្នោតដែលបានរាប់ទាំងពីរពំនូក ដល់ភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ ។

ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលបានរាប់ពីហិបឆ្នោត ជាមួយនឹងចំនួនដែលបានកត់ត្រាក្នុងទម្រង់បែបបទដែលបានបំពេញ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៨៣ នៃច្បាប់នេះ រួចហើយត្រូវបង្ហាញលទ្ធផលនៃការផ្ទៀងផ្ទាត់នេះដល់ភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ ដើម្បីឱ្យអ្នកទាំងនោះអាចពិនិត្យតាមដាននិងវាយតម្លៃលទ្ធផលនោះបាន ។

មាត្រា ១៨៩.-

មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតត្រូវផ្ទារសន្លឹកឆ្នោតដែលមានបោះត្រាខាងខ្នងនៅពីទូ ទី ១ ដូចមានចែងក្នុងមាត្រា ១៨៨ នៃច្បាប់នេះ រួចហើយត្រូវបំបែកសន្លឹកឆ្នោតទាំងនេះជាសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ។

សន្លឹកឆ្នោតមិនបានការជាសន្លឹកឆ្នោតដែល :

- មិនបានផ្តល់ឱ្យដោយមន្ត្រីការិយាល័យបោះឆ្នោត
- គូសឱ្យបញ្ជីបេក្ខជនច្រើនជាងមួយ
- មិនមានគូស
- គូសមិនច្បាស់លាស់
- រហែកឬខូច ។

បន្ទាប់មក មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតត្រូវរាប់សន្លឹកឆ្នោតបានការដែលបានគូសឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ។

សន្លឹកឆ្នោតត្រូវរាប់ទៅតាមវិធីមួយ ដែលអាចមើលឃើញគំនូសនៃការបោះឆ្នោតទាំងអស់ ដោយភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ ។

មាត្រា ១៩០.-

នៅពេលមានការជំទាស់ចំពោះសន្លឹកឆ្នោតដែលបានរាប់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១៨៩ នៃច្បាប់នេះ សន្លឹកឆ្នោតដែលមានការជំទាស់នោះត្រូវដាក់ដាច់ដោយឡែកហើយដោះស្រាយទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១៩១ នៃច្បាប់នេះ ។

មាត្រា ១៩១.-

មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតត្រូវពិនិត្យមើលគ្រប់សន្លឹកឆ្នោតមិនបានការនិងសន្លឹកឆ្នោតដែលមានការជំទាស់ តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១៨៩ និងមាត្រា ១៩០ នៃច្បាប់នេះ ។

ការពិនិត្យសន្លឹកឆ្នោតនេះត្រូវធ្វើជាចំហចំពោះមុខភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ និងសុំឱ្យអ្នកទាំងនោះផ្តល់មតិយោបល់ ។

បន្ទាប់ពីបានពិចារណាលើមតិយោបល់ទាំងនេះហើយ មន្ត្រីរាប់សន្លឹកឆ្នោតដែលបានទទួលការតែងតាំងត្រូវសម្រេចបដិសេធចោលនិងមិនរាប់សន្លឹកឆ្នោតដែល :

- ពុំមែនជាសន្លឹកឆ្នោតដែលផ្តល់ឱ្យដោយការិយាល័យបោះឆ្នោត
- គ្មានត្រាសម្គាល់ជាផ្លូវការ
- គូសឱ្យបញ្ជីបេក្ខជនលើសពីមួយ
- គ្មានគំនូស
- មានគំនូសប៉ុន្តែមិនអាចយកជាការបាន ដោយគំនូសនោះមិនអាចឱ្យមន្ត្រីរាប់សន្លឹកឆ្នោតសម្រេចថា តើគូសឱ្យបញ្ជីបេក្ខជនណាមួយ
- មានសញ្ញាដែលនាំឱ្យគេស្គាល់អ្នកបោះឆ្នោត
- រហែកឬខូចមិនអាចយកជាការបាន ។

សន្លឹកឆ្នោតដែលបានសម្រេចទទួលយកតាមមាត្រានេះ ត្រូវយកមករាប់បូកជាមួយនឹងសន្លឹកឆ្នោតបានការដែលបានរាប់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី៣ និងទី៤ មាត្រា ១៨៩ នៃច្បាប់នេះ ទោះបីជាមាន ឬគ្មានការជំទាស់ទៅនឹងការសម្រេចទទួលយកនោះក្តី ។

មាត្រា ១៩២.-

បន្ទាប់ពីបានបំពេញតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១៨៨ ១៨៩ ១៩០ និងមាត្រា ១៩១ នៃច្បាប់នេះ ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវធ្វើកំណត់ហេតុស្តីពីលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោតសម្រាប់ការិយាល័យរបស់ខ្លួន ទៅតាមបទបញ្ជានិងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងដាក់បង្ហាញលទ្ធផលបណ្តោះអាសន្ននេះដល់ភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ ។

ភ្នាក់ងារនៃគណបក្សនយោបាយត្រូវចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សីលើកំណត់ហេតុខាងលើនេះ ។

កំណត់ហេតុស្តីពីលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោតនោះ ត្រូវកត់ត្រាចំនួនសន្លឹកឆ្នោតដែលបានរាប់ពីហិបឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានបដិសេធចោលមិនបានរាប់ ចំនួនសន្លឹកឆ្នោតបានការដែលបានរាប់ ចំនួនសន្លឹកឆ្នោតខូច ចំនួនសន្លឹកឆ្នោតនៅសល់និងចំនួនសន្លឹកឆ្នោតដែលបានបោះឱ្យបញ្ជីបេក្ខជននីមួយៗ ទៅតាមលំដាប់ឈ្មោះនៅលើសន្លឹកឆ្នោត ។

កំណត់ហេតុស្តីពីលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ ត្រូវស្ថិតក្រោមការត្រួតពិនិត្យឡើងវិញដោយគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់លើ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

មាត្រា ១៩៣.-

កំណត់ហេតុស្តីពីការរាប់សន្លឹកឆ្នោតដូចមានចែងក្នុងមាត្រា ១៩២ នៃច្បាប់នេះត្រូវធ្វើជា ៣ ច្បាប់ :

- មួយច្បាប់ផ្ញើជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ដោយភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះអ្នកបោះឆ្នោត គល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ សន្លឹកឆ្នោតមិនបានប្រើ សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតពុំបានការ សន្លឹកឆ្នោតខូច ហិបឆ្នោត ត្រាសម្ងាត់សម្រាប់ការិយាល័យបោះឆ្នោត បណ្តឹងជំទាស់ឬតវ៉ាប្រសិនបើមាន និងឯកសារ សម្ភារៈឧបករណ៍ចាំបាច់ផ្សេងៗទៀតដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

សម្ភារៈ ឧបករណ៍និងឯកសារខាងលើនេះត្រូវរៀបចំ ឬច្រកក្នុងស្រោមសំបុត្រដោយដែកៗពីគ្នា តាមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- មួយច្បាប់ បិទផ្សាយជាសាធារណៈនៅការិយាល័យរាប់សន្លឹកឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត

- មួយច្បាប់ទៀត បិទផ្សាយជាសាធារណៈនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

មាត្រា ១៩៤.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់ឱ្យបានជាក់ស្តែងបន្ថែមទៀតនូវ :

- នីតិវិធីស្តីពីការរាប់សន្លឹកឆ្នោត

- សេចក្តីណែនាំសម្រាប់ធ្វើកំណត់ហេតុពេលរាប់សន្លឹកឆ្នោត ក្នុងការិយាល័យរាប់សន្លឹកឆ្នោត

- របៀបប្រមូលផ្តុំ វេចខ្ចប់និងរាយមុខសម្ភារៈបោះឆ្នោតឱ្យបានត្រឹមត្រូវសម្រាប់ការប្រគល់ ការទទួលនិងរាយការណ៍ដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

- នីតិវិធីសម្រាប់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ត្រួតពិនិត្យកំណត់ហេតុ

រាប់សន្លឹកឆ្នោត បូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យរាប់សន្លឹកឆ្នោត និងការត្រួតពិនិត្យឧបករណ៍ សម្ភារៈបោះឆ្នោតដែលបានទទួលពីគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត ។

មាត្រា ១៩៥.-

ក្នុងករណីមានការសម្រេចពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេងពីការិយាល័យបោះឆ្នោត ការរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេងនោះត្រូវអនុវត្តទៅតាមនីតិវិធីដូចមានចែងក្នុងមាត្រា ១៨៨ ១៨៩ ១៩០ ១៩១ ១៩២ ១៩៣ និងមាត្រា ១៩៤ នៃច្បាប់នេះ ។

មាត្រា ១៩៦.-

បន្ទាប់ពីបានបំពេញកំណត់ហេតុរាប់សន្លឹកឆ្នោតនិងប្រមូលសម្ភារៈបោះឆ្នោតរួចរាល់ហើយ មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតត្រូវនាំយកកំណត់ហេតុនិងសម្ភារៈបោះឆ្នោតទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

ភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ ត្រូវបានអនុញ្ញាតចូលរួមក្នុងការដឹកជញ្ជូន និងការប្រគល់ ការទទួលកំណត់ហេតុរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈបោះឆ្នោតខាងលើនេះ ។

មាត្រា ១៩៧.-

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវមានវត្តមាននៅទីស្នាក់ការរបស់ខ្លួនដើម្បីរង់ចាំទទួលកំណត់ហេតុរាប់សន្លឹកឆ្នោតនិងសម្ភារៈបោះឆ្នោតពីគ្រប់ការិយាល័យរាប់សន្លឹកឆ្នោតចាប់ពីម៉ោង ១៥:០០នាទីរហូតដល់បានទទួលកំណត់ហេតុរាប់សន្លឹកឆ្នោត និងសម្ភារៈបោះឆ្នោតពីគ្រប់ការិយាល័យរាប់សន្លឹកឆ្នោតចំណុះឃុំ សង្កាត់របស់ខ្លួន ។

នៅពេលគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតទទួលកំណត់ហេតុរាប់សន្លឹកឆ្នោតនិងសម្ភារៈបោះឆ្នោតទាំងអស់ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចុះហត្ថលេខាលើទម្រង់បែបបទ ប្រគល់ ទទួល រួចហើយប្រគល់ជូនប្រធានការិយាល័យរាប់សន្លឹកឆ្នោតមួយច្បាប់និងទុកជាឯកសារមួយច្បាប់ ។

ទម្រង់បែបបទប្រគល់ ទទួលខាងលើនេះត្រូវឱ្យភ្នាក់ងារនៃគណបក្សនយោបាយចូលរួម ចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី ។

មាត្រា ១៩៨.-

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវត្រួតពិនិត្យនិងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោតតាមការិយាល័យរាប់សន្លឹកឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៣( បី)ថ្ងៃ បន្ទាប់ពីបានទទួលកំណត់ហេតុនៃការបោះឆ្នោត និងសម្ភារៈបោះឆ្នោតពីគ្រប់ការិយាល័យរាប់សន្លឹកឆ្នោតទាំងអស់ ។

ក្នុងការត្រួតពិនិត្យនិងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោត គណៈកម្មការឃុំ សង្កាត់មិនអាចបើកកញ្ចប់សន្លឹកឆ្នោត និងមិនអាចរាប់សន្លឹកឆ្នោតឡើងវិញបានឡើយ ចំពោះការិយាល័យរាប់សន្លឹកឆ្នោតណាដែលគ្មានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់អំពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ។

ភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងដំណើរការត្រួតពិនិត្យនិងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈបោះឆ្នោត ដែលបានប្រមូលមកពីគ្រប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ ។

មាត្រា ១៩៩.-

កំណត់ហេតុរាប់សន្លឹកឆ្នោតនិងសម្ភារៈបោះឆ្នោតដែលបានទទួលពីការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ត្រូវកត់ចំណាំនិងទុកដាក់ដោយឡែកតាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ទៅតាមទម្រង់បែបបទដែលកំណត់ដោយបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

កំណត់ហេតុខាងលើនេះត្រូវធ្វើជាបីច្បាប់ :

- មួយច្បាប់ផ្ញើជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ដោយភ្ជាប់ជាមួយនូវបញ្ជីឈ្មោះអ្នកបោះឆ្នោត ពល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ សន្លឹកឆ្នោតមិនបានប្រើ សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ សន្លឹកឆ្នោតខូច ត្រាសម្ងាត់សម្រាប់បោះលើសន្លឹកឆ្នោតតាម

ការិយាល័យបោះឆ្នោត ពាក្យបណ្តឹងជំទាស់ ឬតវ៉ាប្រសិនបើមាន ព្រមទាំងសម្ភារៈឯកសារផ្សេងៗទៀត

- មួយច្បាប់បិទនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត

- មួយច្បាប់ទុកជាឯកសារ ។

មាត្រា ២០០.-

ក្នុងករណីមានបណ្តឹងជំទាស់ ឬបណ្តឹងតវ៉ាអំពីភាពមិនប្រក្រតី ដែលអាចប៉ះពាល់ដល់លទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យនោះ នៅចំពោះមុខភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ដោយ :

- ពិនិត្យលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រគល់ឱ្យការិយាល័យបោះឆ្នោត ជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលទទួលពីការិយាល័យនោះមកវិញ

- ពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានមកបោះឆ្នោត

- ពិនិត្យនិងរាប់សន្លឹកឆ្នោតបានការដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ

- ពិនិត្យសន្លឹកឆ្នោតមិនបានការ

- រាប់សន្លឹកឆ្នោតខូច

- រាប់សន្លឹកឆ្នោតដែលមិនបានប្រើប្រាស់

- ពិនិត្យមើលត្រាសម្ងាត់ជាផ្លូវការដែលបានប្រគល់ដល់ការិយាល័យបោះឆ្នោតនោះ

- ពិនិត្យមើលហិបឆ្នោតនិងសញ្ញាសម្គាល់ ឬលេខសម្គាល់ហិបឆ្នោតរបស់ការិយាល័យបោះឆ្នោតនោះ ផ្ទៀងផ្ទាត់ជាមួយសញ្ញាសម្គាល់ឬលេខសម្គាល់ហិបឆ្នោតដែលបានប្រគល់ដល់ការិយាល័យបោះឆ្នោតនោះ ។

សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ សន្លឹកឆ្នោតខូចត្រូវចងជាជុំៗ តាមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បន្ទាប់ពីការត្រួតពិនិត្យខាងលើនេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវធ្វើសេចក្ដីរាយការណ៍និងលើកយោបល់ភ្ជាប់ជាមួយកំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតដើម្បីពិនិត្យនិងសម្រេច ។

មាត្រា ២០១.-

នៅពេលគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតទទួលកំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវចុះហត្ថលេខាលើទម្រង់បែបបទប្រគល់ ទទួល រួចប្រគល់ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតមួយច្បាប់និងទុកជាឯកសារមួយច្បាប់ ។

មាត្រា ២០២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតាក់តែងបទបញ្ជានិងនីតិវិធីដើម្បីអនុវត្តជាបន្ថែមទៀត សម្រាប់ការគ្រប់គ្រងនិងការប្រព្រឹត្តទៅនៃការរាប់សន្លឹកឆ្នោត ឱ្យបានត្រឹមត្រូវស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ២០៣.-

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវត្រួតពិនិត្យនូវលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលកំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗនោះ ។

ក្នុងការត្រួតពិនិត្យនូវលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតរបស់ឃុំ សង្កាត់នីមួយៗ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតមិនអាចបើកកញ្ចប់សន្លឹកឆ្នោតនៃឃុំ សង្កាត់ណាមួយ ឬការិយាល័យបោះឆ្នោតណាមួយបានឡើយ ប្រសិនបើឃុំ សង្កាត់នោះ ឬការិយាល័យបោះឆ្នោតនោះគ្មានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់អំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ។

ចំពោះឃុំ សង្កាត់ណា ឬការិយាល័យបោះឆ្នោតណាដែលមានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតអាចបើកនិងពិនិត្យមើលសម្ភារៈបោះឆ្នោតនិងអាចរាប់សន្លឹកឆ្នោតឡើងវិញ ប្រសិនបើចាំបាច់ ។

ក្នុងករណីឃុំ សង្កាត់ណាដែលមានសម្លេងឆ្នោតលម្អៀងគ្នាយ៉ាងច្រើន ០,៥ ភាគរយរវាងបញ្ជីបេក្ខជនពីរ ឬច្រើន ហើយឃុំ សង្កាត់នោះមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែលមានលក្ខណៈសមស្របតាមលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ២១០ នៃច្បាប់នេះ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបើកពិនិត្យមើលសម្ភារៈបោះឆ្នោតនិងរាប់សន្លឹកឆ្នោតឡើងវិញ ។

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតសាមី ភ្នាក់ងារនៃគណបក្សនយោបាយអ្នកសង្កេតការណ៍នៃឃុំ សង្កាត់នោះ និងអ្នកជំទាស់ដូចមានចែងក្នុងមាត្រា ២១០ នៃច្បាប់នេះ អាចចូលរួមក្នុងដំណើរការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ នោះ ដោយគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ។

បន្ទាប់ពីបានត្រួតពិនិត្យនូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់ឃុំ សង្កាត់នីមួយៗចប់សព្វគ្រប់ហើយ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវធ្វើការកំណត់ចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល និងត្រូវស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ និងកំណត់ឈ្មោះបេក្ខជនជាប់ឆ្នោតដែលទទួលតំណែងជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ស្របតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៣២ ៣៣ ៣៤ និងមាត្រា ៣៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ រួចហើយធ្វើសេចក្តីរាយការណ៍ភ្លាមទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមទម្រង់បែបបទដែលបានកំណត់ ។

ក្នុងការកំណត់បេក្ខជនជាប់ឆ្នោតទទួលតំណែងជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ជាមេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ករណីបើមានបញ្ជីបេក្ខជននៃគណបក្សនយោបាយពីរឬច្រើនមានសំឡេងឆ្នោតស្មើគ្នា គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវរៀបចំការចាប់ឆ្នោត ទៅតាមនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

# ជំពូកទី ១២

## លទ្ធផលបណ្ដោះអាសន្ន លទ្ធផលជាផ្លូវការនិងការជំទាស់ចំពោះ
## លទ្ធផលនៃការបោះឆ្នោត

មាត្រា ២០៤.-

ក្នុងការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ ករណីពិនិត្យឃើញភាពមិនប្រក្រតីដែលមិនអាចនាំទៅដល់ការផ្លាស់ប្ដូរលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតទេ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបំពេញបែបបទយល់ព្រមនិងចុះហត្ថលេខា ហើយដាក់បង្ហាញការយល់ព្រមរបស់ខ្លួនចំពោះលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ដល់ភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍ ។

មាត្រា ២០៥.-

ក្នុងករណីមានភាពមិនប្រក្រតីដែលនាំឱ្យមានការផ្លាស់ប្ដូរដល់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវល្បួរលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនោះ រួចហើយត្រូវបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ឬនៅការិយាល័យបោះឆ្នោតនោះដោយ :

- ប្រកាសថាលទ្ធផលនៃការបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ ឬនៅការិយាល័យនោះត្រូវបានបដិសេធ

- បំពេញទម្រង់បែបបទជូនដំណឹងស្ដីពីសេចក្ដីសម្រេចលើបណ្ដឹង ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ចុះហត្ថលេខានិងកាលបរិច្ឆេទលើទម្រង់បែបបទនោះ

- ប្រកាសថាសេចក្ដីសម្រេចរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតស្ថិតក្រោមការត្រួតពិនិត្យឡើងវិញនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- ផ្ញើទម្រង់បែបបទជូនដំណឹងស្ដីពីសេចក្ដីសម្រេចលើបណ្ដឹងជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនអ្នកប្ដឹងជំទាស់មួយច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជននៅក្នុងឃុំ សង្កាត់ពាក់ព័ន្ធនោះមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

មាត្រា ២០៦.-

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបញ្ជូនលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចនៃការបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ឬការិយាល័យបោះឆ្នោតណាមួយ មិនឱ្យលើសពី ២៤(ម្ភៃបួន)ម៉ោងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដើម្បីត្រួតពិនិត្យឡើងវិញ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវត្រួតពិនិត្យឡើងវិញ និងសម្រេចលើសេចក្តីសម្រេចនៃការបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត មិនឱ្យលើសពី ៤(បួន)ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទជូនដំណឹងស្តីពីសេចក្តីសម្រេចលើពាក្យបណ្តឹង ។

មាត្រា ២០៧.-

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនយល់ព្រមលើសេចក្តីសម្រេចនៃការបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

- ប្រកាសថាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់នោះត្រូវបានចាត់ទុកថាត្រឹមត្រូវ
- បំពេញទម្រង់បែបបទដែលបានកំណត់ដោយបញ្ជាក់ពីមូលហេតុនៃការមិនយល់ព្រមចំពោះសេចក្តីសម្រេចរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទលើទម្រង់បែបបទនោះ
- ផ្ញើទម្រង់បែបបទនោះជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនអ្នកប្តឹងមួយច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជននៅក្នុងឃុំ សង្កាត់នោះមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

មាត្រា ២០៨.-

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទទួលយល់ព្រមលើសេចក្តីសម្រេចនៃការបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការ

បោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

- ប្រកាសថាលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់នោះត្រូវបានបដិសេធ

- បំពេញទម្រង់បែបបទដែលបានកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត រួចហើយចុះហត្ថលេខានិងកាលបរិច្ឆេទលើទម្រង់បែបបទនោះ

- ផ្ញើទម្រង់បែបបទនោះជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនអ្នកប្ដឹងមួយច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជននៅក្នុងឃុំ សង្កាត់នោះមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

មាត្រា ២០៩.-

ក្នុងករណីដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ឬការិយាល័យបោះឆ្នោតណាមួយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យធ្វើការបោះឆ្នោតសាជាថ្មី មិនលើសពី ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ។

ការបោះឆ្នោតសាជាថ្មីត្រូវធ្វើឡើងនៅក្នុងការិយាល័យបោះឆ្នោតដដែល ដោយយកបញ្ជីឈ្មោះអ្នកបោះឆ្នោតដដែល ព្រមទាំងបញ្ជីបេក្ខជននៃគណបក្សនយោបាយដដែល ដូចគ្នានឹងការបោះឆ្នោតលើកមុន ។

បទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ៨ ៩ ១០ ១១ និងជំពូកទី ១២ នៃច្បាប់នេះ ត្រូវបានអនុវត្តចំពោះការបោះឆ្នោតសាជាថ្មីនេះ លើកលែងតែសន្លឹកឆ្នោតដែលត្រូវបោះពុម្ពលើក្រដាសពណ៌ផ្សេងពីលើកមុន ។

មាត្រា ២១០.-

ជនគ្រប់រូបដែលបានចុះឈ្មោះបោះឆ្នោតនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈររឈ្មោះមានសិទ្ធិប្ដឹងជំទាស់ទៅគណៈ-កម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត អំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ

សង្កាត់ ឬការិយាល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់នោះ ។

ការប្តឹងជំទាស់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៣(បី)ថ្ងៃ បន្ទាប់ពីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ។

ការប្តឹងជំទាស់ត្រូវផ្អែកលើភាពមិនប្រក្រតីក្នុងដំណើរការនៃការបោះឆ្នោត ដែលនាំឱ្យផ្លាស់ប្តូរដល់លទ្ធផលនៃការបោះឆ្នោត ។

ការប្តឹងជំទាស់ត្រូវមានមូលដ្ឋានច្បាស់លាស់ ដោយបង្ហាញអំពីទីកន្លែងនិងពេលវេលាដែលមានភាពមិនប្រក្រតី ឈ្មោះនិងអាសយដ្ឋានរបស់សាក្សី និងសេចក្តីអះអាងគាំទ្រឬភស្តុតាងផ្សេងទៀត ។

គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវសម្រេចលើការប្តឹងជំទាស់នេះ ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យប្តឹងជំទាស់ ។

មាត្រា ២១១.-

ក្នុងករណីគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតរកឃើញថា ការប្តឹងជំទាស់ពុំមានមូលដ្ឋានសមហេតុសមផល ឬពុំមានឥទ្ធិពលធ្វើឱ្យផ្លាស់ប្តូរដល់លទ្ធផលនៃការបោះឆ្នោត គណៈ-កម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបដិសេធការប្តឹងជំទាស់នោះដោយ :

- ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ថាការប្តឹងជំទាស់នោះត្រូវបានបដិសេធ
- បំពេញទម្រង់បែបបទបដិសេធតាមការកំណត់ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ រួចហើយចុះហត្ថលេខានិងកាលបរិច្ឆេទលើទម្រង់បែបបទនោះ
- ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ថា សាមីខ្លួនឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចបដិសេធរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៤(បួន)ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទបដិសេធ
- ផ្តល់ទម្រង់បែបបទដល់អ្នកប្តឹងជំទាស់ឬតំណាងសម្រាប់ប្តឹងតវ៉ា
- ផ្ញើទម្រង់បែបបទបដិសេធដែលបានបំពេញរួច ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់ពាក់ព័ន្ធមួយច្បាប់ ជូនអ្នកប្តឹងជំទាស់មួយច្បាប់ ជូនតំណាងគណបក្សនយោបាយដែលមានបេក្ខជនក្នុងឃុំ សង្កាត់នោះមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

មាត្រា ២១២.-

ក្នុងករណីគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតយល់ព្រមចំពោះការប្តឹងជំទាស់ គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតត្រូវបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះដោយ :

- ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ថាការប្តឹងជំទាស់នោះត្រូវបានយល់ព្រម

- ប្រកាសថាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ឬក្នុងការិយា-ល័យបោះឆ្នោតណាមួយនៃឃុំ សង្កាត់នោះត្រូវបានបដិសេធ

- បំពេញទម្រង់បែបបទបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមការកំណត់ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធលទ្ធផលនៃការបោះឆ្នោតនោះ រួចហើយចុះហត្ថលេខានិងកាលបរិច្ឆេទ

- ប្រកាសថាសេចក្តីសម្រេចរបស់គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតស្ថិតក្រោមការត្រួតពិនិត្យឡើងវិញដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- ផ្ញើទម្រង់បែបបទបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជូនគណៈកម្មា-ធិការជាតិរៀបចំការបោះឆ្នោតមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតមួយច្បាប់ ជូនអ្នកជំទាស់មួយច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជននៅក្នុងឃុំ សង្កាត់នោះមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

មាត្រា ២១៣.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវត្រួតពិនិត្យឡើងវិញនូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ឬក្នុងការិយាល័យបោះឆ្នោតណាមួយដែលមានការប្តឹងជំទាស់ ក្នុងរយៈពេលយ៉ាងយូរ ៤(បួន)ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទប្តឹងតវ៉ាដូចមានចែងក្នុងមាត្រា ២១១ នៃច្បាប់នេះ ឬទម្រង់បែបបទបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ដូចមានចែងក្នុងមាត្រា ២១២ នៃច្បាប់នេះ ។

ក្នុងការត្រួតពិនិត្យឡើងវិញនូវលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ណាមួយ ឬការិយាល័យបោះឆ្នោតណាមួយដែលមានការប្តឹងជំទាស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចបើកពិនិត្យមើលសម្ភារៈបោះឆ្នោតនិងអាចរាប់សន្លឹកឆ្នោតនៅឃុំ សង្កាត់នោះ ឬការិយាល័យបោះឆ្នោតនោះឡើងវិញ ប្រសិនបើចាំបាច់ ។

ក្នុងករណីឃុំ សង្កាត់ណាដែលមានសម្លេងឆ្នោតលម្អៀងយ៉ាងច្រើន ០,៥ ភាគរយរវាងបញ្ជីបេក្ខជនពីរឬច្រើន ហើយឃុំ សង្កាត់នោះមានពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ដែលមានលក្ខណៈសមស្របតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២១០ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបើកពិនិត្យមើលសម្ភារៈបោះឆ្នោតនិងរាប់សន្លឹកឆ្នោតឡើងវិញ ។

ដំណើរការត្រួតពិនិត្យលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតខាងលើនេះ ត្រូវធ្វើចំពោះមុខភ្នាក់ងារនៃគណបក្សនយោបាយ អ្នកសង្កេតការណ៍និងអ្នកប្តឹងជំទាស់ដែលមានការពាក់ព័ន្ធ ។

## មាត្រា ២១៤.-

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតរកឃើញថា ការប្តឹងជំទាស់ទាក់ទងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ឬការិយាល័យបោះឆ្នោតណាមួយពុំមានមូលដ្ឋានសមហេតុសមផល ឬពុំមានឥទ្ធិពលធ្វើឱ្យផ្លាស់ប្តូរដល់លទ្ធផលនៃការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបដិសេធការប្តឹងជំទាស់នោះដោយ :

- ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ ឬតំណាងថាការប្តឹងជំទាស់នោះត្រូវបានបដិសេធ
- ប្រកាសថាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬការិយាល័យនោះត្រូវបានចាត់ទុកថាត្រឹមត្រូវ
- បំពេញទម្រង់បែបបទបដិសេធការប្តឹងជំទាស់ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ រួចហើយចុះហត្ថលេខានិងកាលបរិច្ឆេទលើទម្រង់បែបបទនោះ
- ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ ឬតំណាងថាសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសេចក្តីសម្រេចចុងក្រោយ
- ផ្ញើទម្រង់បែបបទបដិសេធដែលបានបំពេញរួចជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនអ្នកប្តឹងជំទាស់មួយច្បាប់ ជូនតំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនក្នុងឃុំ សង្កាត់នោះមួយច្បាប់ និងទុកជាឯកសារមួយច្បាប់ ។

## មាត្រា ២១៥.-

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ព្រមចំពោះការប្តឹងជំទាស់ទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ឬការិយាល័យបោះឆ្នោត

ណាមួយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

- ផ្ដល់ដំណឹងដល់អ្នកប្ដឹងជំទាស់ ឬតំណាងថា ការប្ដឹងជំទាស់នោះត្រូវបានយល់ព្រម

- ប្រកាសថាលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ឬការិយាល័យបោះឆ្នោតនោះត្រូវបានបដិសេធ

- បំពេញទម្រង់បែបបទដែលបានកំណត់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធចំពោះលទ្ធផលនៃការបោះឆ្នោតនោះ រួចហើយចុះហត្ថលេខានិងកាលបរិច្ឆេទ

- ផ្ញើទម្រង់បែបបទដែលបានបំពេញរួចជូនគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ ជូនតំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនក្នុងឃុំ សង្កាត់នោះមួយច្បាប់ ជូនអ្នកប្ដឹងជំទាស់មួយច្បាប់និងទុកជាឯកសារមួយច្បាប់ ។

សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសេចក្ដីសម្រេចចុងក្រោយ ។

## មាត្រា ២១៦.-

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ឬការិយាល័យបោះឆ្នោតណាមួយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យអនុវត្តនូវបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ២០៩ នៃច្បាប់នេះ ។

## មាត្រា ២១៧.-

បន្ទាប់ពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗ ពិនិត្យឡើងវិញឃើញថាត្រឹមត្រូវ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវប្រកាសជាសាធារណៈនូវលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះភ្លាម ។

ចំពោះឃុំ សង្កាត់ណាដែលមានបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់អំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ការប្រកាសនូវលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្នុងឃុំ សង្កាត់នោះ ត្រូវធ្វើបន្ទាប់ពីការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់ត្រូវបានដោះស្រាយរួចរាល់ជាស្ថាពរទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់នូវលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ជូននាយករដ្ឋមន្ត្រីមួយច្បាប់ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមួយច្បាប់និងត្រូវបិទផ្សាយជាសាធារណៈនូវលទ្ធផលនេះ នៅទីស្នាក់ការគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតសាមីមួយច្បាប់ នៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតសាមីមួយច្បាប់ និងទុកជាឯកសារមួយច្បាប់ ។

មាត្រា ២១៨.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំទុកដាក់ឱ្យមានសុវត្ថិភាពនូវឯកសារបោះឆ្នោតទាំងអស់ដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដូចខាងក្រោម :

- កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងឯកសារប្តឹងតវ៉ា និងប្តឹងជំទាស់ព្រមទាំងសេចក្តីសម្រេចដោះស្រាយរបស់អាជ្ញាធររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំទុកដាក់ឱ្យមានសុវត្ថិភាពជារៀងរហូត

- បញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសសម្រាប់អាណត្តិនីមួយៗ ត្រូវផ្ញើមួយច្បាប់ទៅតម្កល់ទុកនៅកន្លែងតម្កល់ឯកសាររបស់រដ្ឋ និងមួយច្បាប់ទៀតត្រូវរៀបចំទុកដាក់ឱ្យមានសុវត្ថិភាពនៅទីស្នាក់ការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជារៀងរហូត

- សន្លឹកឆ្នោតទាំងអស់ដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ តាមអាណត្តិនីមួយៗ ត្រូវរៀបចំទុកដាក់ឱ្យមានសុវត្ថិភាពក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីថ្ងៃបោះឆ្នោត ។ បន្ទាប់ពីរយៈពេលនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបង្កើតគណៈកម្មការមួយដើម្បីបំផ្លាញចោលនូវសន្លឹកឆ្នោតទាំងនោះ លើកលែងតែសន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត ឬឃុំ សង្កាត់ណាដែលមានការប្តឹងជំទាស់ ប្តឹងតវ៉ា ។

មាត្រា ២១៩.-

បេក្ខជនដែលបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ស្របតាមច្បាប់នេះនឹងក្លាយទៅជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់អាណត្តិ ៥ឆ្នាំ ចាប់តាំងពីពេលចូលកាន់តំណែង រហើយនឹងត្រូវបញ្ចប់អាណត្តិរបស់ខ្លួនដោយផ្អែកតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

# ជំពូកទី ១៣

# ការបិទការិយាល័យបោះឆ្នោតក្នុងគ្រាមានអាសន្ន

មាត្រា ២២០.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិសម្រេចមិនបើកការិយាល័យបោះឆ្នោត និងមានសិទ្ធិបិទការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួន ក្នុងកាលៈទេសៈមានអាសន្នដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោតនិងអ្នកបោះឆ្នោតនៅក្នុងបរិវេណខាងក្នុង ។

កាលៈទេសៈមានអាសន្នអាចមានករណីណាមួយ ក្នុងចំណោមករណីដូចខាងក្រោម :

- អសន្តិសុខជាសាធារណៈ
- ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយផែនដីឬគ្រោះធម្មជាតិផ្សេងទៀត
- ការដួលរលំអាគារសំរាប់ប្រើការបោះឆ្នោតដោយយថាហេតុណាមួយ អគ្គីភ័យឬការខូចខាតប្រហាក់ប្រហែលគ្នាដែលនាំឱ្យមានគ្រោះថ្នាក់
- ការរាំងស្ទះផ្នែករដ្ឋបាលដែលមិនអាចឱ្យការបោះឆ្នោតដំណើរការបាន ។

ការិយាល័យបោះឆ្នោតដែលមិនបានបើកឬដែលបានបិទតាមមាត្រានេះ ត្រូវតែបិទរយៈពេញមួយថ្ងៃ ។

មាត្រា ២២១.-

ក្នុងករណីការិយាល័យបោះឆ្នោតណាមួយត្រូវបិទ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរាយការណ៍ភ្លាមជូននាយករដ្ឋមន្ត្រី ។

មាត្រា ២២២.-

ក្នុងករណីដែលការិយាល័យបោះឆ្នោតណាមួយត្រូវបិទ ការបោះឆ្នោតនៅការិយាល័យនេះត្រូវធ្វើសាជាថ្មីក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃក្រោយនៅទីកន្លែងសមស្រប ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

អ្នកបោះឆ្នោតទាំងអស់ដែលមានសិទ្ធិបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ត្រូវអនុញ្ញាតឱ្យបោះឆ្នោត ទោះបីជាអ្នកទាំងនោះបានបោះឆ្នោតហើយក្តី ឬមិនទាន់បានបោះឆ្នោតក្តី ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធានាឱ្យមានសន្លឹកឆ្នោតគ្រប់ចំនួនដែលបោះពុម្ពលើក្រដាសពណ៌ផ្សេងពីលើកមុន ។

មាត្រា ២២៣.-

សន្លឹកឆ្នោតដែលបានបោះនៅក្នុងការិយាល័យបោះឆ្នោតដែលបានបិទស្របតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២២០ នៃច្បាប់នេះមិនត្រូវយកមករាប់ឡើយ មានតែសន្លឹកឆ្នោតដែលបានបោះនៅថ្ងៃបោះឆ្នោតដែលត្រូវធ្វើសាជាថ្មីប៉ុណ្ណោះដែលត្រូវយកមករាប់ ។

ចំពោះសន្លឹកឆ្នោតដែលមិនត្រូវយកមករាប់ មន្ត្រីការិយាល័យបោះឆ្នោតត្រូវធ្វើកំណត់ហេតុនិងរៀបចំទុកដាក់ស្របតាមបទបញ្ជានិងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

សន្លឹកឆ្នោតដែលបានបោះនៅគ្រប់ការិយាល័យបោះឆ្នោតដែលមិនបានបិទត្រូវយកមករាប់និងកត់ត្រានៅថ្ងៃបោះឆ្នោត ។

សន្លឹកឆ្នោតទាំងអស់ត្រូវរាប់និងកត់ត្រាតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ។

បន្ទាប់ពីការបោះឆ្នោតសាជាថ្មី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឱ្យបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងមូល និងប្រកាសលទ្ធផលស្របតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ ។

មាត្រា ២២៤.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតាក់តែងនូវបទបញ្ជានិងនីតិវិធីសម្រាប់ការអនុវត្តជាក់ស្តែងបន្ថែមទៀតនូវល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២២០ ២២២ និងមាត្រា ២២៣ នៃច្បាប់នេះ ដែលរួមមាន :

- សុវត្ថិភាពនៃមន្ត្រីបោះឆ្នោត អ្នកបោះឆ្នោត ភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍
- តួនាទីរបស់ភ្នាក់ងារនៃគណបក្សនយោបាយនិងអ្នកសង្កេតការណ៍
- ការប្រគល់ ការថែរក្សា ការទទួលនិងសុវត្ថិភាពនៃសម្ភារៈបោះឆ្នោតទាំងអស់
- ការបិទការិយាល័យបោះឆ្នោតនិងការបើកការិយាល័យបោះឆ្នោតឡើងវិញ

- ដំណើរការបោះឆ្នោតសាជាថ្មី
- ការរាប់សន្លឹកឆ្នោត
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត ។

## ជំពូកទី ១៤
## ការបោះឆ្នោតឡើងវិញ

**មាត្រា ២២៥.-**

ការបោះឆ្នោតឡើងវិញដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវធ្វើឡើងក្នុងរយៈពេលមិនឱ្យលើសពី ១២០(មួយរយម្ភៃ) ថ្ងៃឡើយ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការបោះឆ្នោតឡើងវិញ ក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃ បន្ទាប់ពីមានករណីដែលតម្រូវឱ្យមានការបោះឆ្នោតឡើងវិញ ។

ការបោះឆ្នោតត្រូវចាប់ផ្តើមពីម៉ោង ៧:០០ នាទីដល់ម៉ោង ១៥:០០ នាទី ក្នុងថ្ងៃដដែល ។

**មាត្រា ២២៦.-**

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតសម្រាប់ការបោះឆ្នោតឡើងវិញ លុះត្រាតែមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត មានប័ណ្ណបោះឆ្នោត ឬវិញ្ញាបនបត្រជំនួសប័ណ្ណបោះឆ្នោតដែលមានសុពលភាព ។

បញ្ជីឈ្មោះអ្នកបោះឆ្នោតត្រូវយកបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ ។

អ្នកបោះឆ្នោតដែលបានចុះឈ្មោះម្នាក់ៗ មានសិទ្ធិបោះឆ្នោតតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈសន្លឹកឆ្នោតសម្ងាត់ ។

**មាត្រា ២២៧.-**

ការបោះឆ្នោតឡើងវិញត្រូវប្រព្រឹត្តទៅក្រោមការគ្រប់គ្រងនិងចាត់ចែងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ២២៨.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវទទួលខុសត្រូវចំពោះការបោះឆ្នោតឡើងវិញ។

បទប្បញ្ញត្តិសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់នេះត្រូវអនុវត្តចំពោះការបោះឆ្នោតឡើងវិញដើម្បីជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ថ្មី ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិតាក់តែងបទបញ្ជានិងនីតិវិធី ដើម្បីធានាឱ្យការបោះឆ្នោតឡើងវិញប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ។

## ជំពូកទី ១៥
## ថវិកា

មាត្រា ២២៩.-

ត្រូវបានបង្កើតគណនីពិសេសរបស់រតនាគារជាតិ ជាគណនីមូលនិធិទាយជ្ជទានការបោះឆ្នោត សម្រាប់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយកទៅចាត់ចែងក្នុងកិច្ចការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អនុលោមទៅតាមច្បាប់ហិរញ្ញវត្ថុ ។

មូលនិធិទាយជ្ជទានការបោះឆ្នោតដែលបានមកពីវិភាគទានផ្សេងៗរបស់រដ្ឋាភិបាល ជំនួយរបស់រដ្ឋាភិបាលបរទេស អង្គការអន្តរជាតិនានា អំណោយពីសប្បុរសជន អំណោយពីអង្គការក្រៅរដ្ឋាភិបាលនិងចំណូលស្របច្បាប់ផ្សេងៗ ត្រូវបញ្ចូលក្នុងថវិកាជាតិដើម្បីផ្តល់ផ្ទាល់ឱ្យទៅគណនីពិសេសនេះ ។

ហិរញ្ញប្បទានក្រៅប្រទេសមួយចំនួនសម្រាប់ការបោះឆ្នោត អាចអនុវត្តដោយប្រតិបត្តិការក្រៅរតនាគារជាតិ ។

បទដ្ឋានចំណូលចំណាយនិងនីតិវិធីសម្រាប់អនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ទាប់ពីបានពិគ្រោះយោបល់ឯកភាពជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

# ជំពូកទី ១៦
# ទោសប្បញ្ញត្តិ

មាត្រា ២៣០.-

ត្រូវស្តីបន្ទោសឬបណ្តេញចេញពីការងារដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងៗទៀត ចំពោះមន្ត្រីចុះឈ្មោះបោះឆ្នោតណាដែលប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

- បានចុះឈ្មោះប៉ុន្តែមិនព្រមប្រគល់ប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតឱ្យប្រជាពលរដ្ឋ

- បានចេញប័ណ្ណបោះឆ្នោតឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតដោយចេតនាដល់អ្នកដែលពុំទាន់គ្រប់អាយុបោះឆ្នោត ឬដល់អ្នកដែលពុំទាន់បំពេញល័ក្ខខ័ណ្ឌគ្រប់គ្រាន់ឱ្យចុះឈ្មោះបោះឆ្នោត

- បានចុះឈ្មោះនិងបានប្រគល់ប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតដោយចេតនាទៅអ្នកដែលត្រូវបានដកសិទ្ធិបោះឆ្នោត

- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យចុះឈ្មោះបោះឆ្នោត

- រារាំងប្រជាពលរដ្ឋមិនឱ្យទទួលប័ណ្ណបោះឆ្នោតឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតក្រោយពេលបានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតរួចហើយ ។

មាត្រា ២៣១.-

ត្រូវដកហូតប័ណ្ណបោះឆ្នោតឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត និងលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម :

- ប្រើកម្លាំងឬអំពើហិង្សា ឬបំភិតបំភ័យមិនឱ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះ ឬទៅចុះឈ្មោះបោះឆ្នោត ឬទទួលប័ណ្ណបោះឆ្នោតឬវិញ្ញាបនប័ត្រ

ជិនូសប័ណ្ណបោះឆ្នោត

- ញុះញង់អ្នកគាំទ្រឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើវិលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើបញ្ជីបេក្ខជននៃគណបក្សនយោបាយដទៃ

- ធ្វើការគាបសង្កត់ឬគំរាមកំហែង ឬបង្ខំធ្វើសម្បថឱ្យគេបោះឆ្នោតឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់ខ្លួន ឬឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយដែលខ្លួនចូលចិត្ត

- ប្រើកម្លាំងឬអំពើហិង្សាដើម្បីរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត

- រារាំងបញ្ជីបេក្ខជននៃគណបក្សនយោបាយឬបេក្ខជននៃបញ្ជីណាមួយ និងអ្នកគាំទ្រមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់

- ប្រើកម្លាំងឬហិង្សា ឬបំភិតបំភ័យ ប្រើពាក្យសំដីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត

- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន

- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន

- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត

- ទិញសន្លឹកឆ្នោតដោយសម្ភារៈឬដោយប្រាក់កាស

- ដកហូតប័ណ្ណបោះឆ្នោតឬវិញ្ញាបនប័ត្រជិនូសប័ណ្ណបោះឆ្នោតពីអ្នកដទៃ ។

មាត្រា ២៣២.-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០(ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល និងត្រូវបញ្ឈប់ពីការងារបោះឆ្នោតជារៀងរហូត ចំពោះសមាជិកឬមន្ត្រីបុគ្គលិកនៃគណៈកម្មាធិការជាតិ សមាជិកឬមន្ត្រីបុគ្គលិកនៃគណៈកម្មការរៀបចំការបោះឆ្នោត មន្ត្រីការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត និងមន្ត្រីការិយាល័យបោះឆ្នោតណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៨ នៃច្បាប់នេះ ។

មាត្រា ២៣៣.-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០(ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត និងដកហូតប័ណ្ណបោះឆ្នោត

សម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំ លុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ចំពោះសមាជិកគណៈកម្មាធិការជាតិ សមាជិកគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត មន្ត្រីការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោត មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតណាដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិចដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត ។

មាត្រា ២៣៤.-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលប្រព្រឹត្តអំពើលួងលោម ទិញទឹកចិត្ត ឬគំរាមកំហែង ឬបំភិតបំភ័យ ឬប្រើអំពើហិង្សារារាំងមិនឱ្យប្រជាពលរដ្ឋដែលមានលក្ខណសម្បត្តិស្របតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ ឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ករណីជនល្មើសជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដកហូតប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត នឹងលុបបេក្ខភាពសាមីខ្លួនចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយ បន្ថែមពីលើទណ្ឌកម្មខាងលើ ។

ករណីជនល្មើសជាសមាជិកឬមន្ត្រីបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ មន្ត្រីការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត និងមន្ត្រីការិយាល័យបោះឆ្នោតត្រូវបញ្ឈប់ពីការងារបោះឆ្នោតជារៀងរហូត បន្ថែមពីលើទណ្ឌ-កម្មខាងលើ ។

មាត្រា ២៣៥.-

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៩ នៃច្បាប់នេះ ។

ក្នុងករណីពុំព្រមអនុវត្តតាមការព្រមាននេះ ត្រូវដកហូតអាវុធជាតិផ្ទុះ ឬសារធាតុនិងវត្ថុប្រកបដោយគ្រោះថ្នាក់ដោយភ្នាក់ងារមានសមត្ថកិច្ច ដើម្បីផ្តន្ទាទោសតាមច្បាប់និងពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន) រៀល ប្រសិនបើជនល្មើសនោះជាមន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

- ស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនដើម្បីឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីការដាក់ឱ្យនៅទំនេរគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែង យោលទៅតាមកម្រិតនៃបទល្មើស

- លុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ដកហូតប័ណ្ណបោះឆ្នោតឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត ។

ក្នុងករណីជនល្មើសជាសមាជិកឬមន្ត្រីបុគ្គលិករបស់គណៈកម្មាធិការជាតិ ឬគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត ឬមន្ត្រីការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ឬមន្ត្រីការិយាល័យបោះឆ្នោត ឬមន្ត្រីការិយាល័យរាប់សន្លឹកឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះមិនឱ្យចូលបំពេញការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោត ឬការិយាល័យចុះឈ្មោះអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោត សម្រាប់រយៈពេល ១០(ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះតទៅ បន្ថែមពីលើទណ្ឌកម្មខាងលើ ។

### មាត្រា ២៣៦.-

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៤០ ៤១ ៤២ ៤៤ ៤៥ និងមាត្រា ៤៦ នៃច្បាប់នេះ ។

ក្នុងករណីពុំព្រមអនុវត្តតាម ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀលទៅ ១០.០០០.០០០(ដប់លាន) រៀល ។

ក្នុងករណីជនល្មើសជាបេក្ខជនក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ត្រូវដកហូតប័ណ្ណបោះឆ្នោតឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត លុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោល បន្ថែមពីលើទណ្ឌកម្មខាងលើ ។

### មាត្រា ២៣៧.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវដកហូតប័ណ្ណបោះឆ្នោតឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតសម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំ លុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីការដាក់ឱ្យទំនេរគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែង ចំពោះមន្ត្រីរាជការឬអ្នកទទួលខុសត្រូវដែលប្រព្រឹត្តល្មើសនឹងមាត្រា ១៧ នៃច្បាប់នេះ ។

មាត្រា ២៣៨.-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវដកហូតប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតសម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ លុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ចំពោះជនណាដែលបង្ខាំបញ្ជាឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកបញ្ជីបេក្ខជននៃគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត ។

ក្នុងករណីជនល្មើសជាសមាជិកឬមន្ត្រីបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬរបស់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬមន្ត្រីការិយាល័យបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារនិងមិនឱ្យចូលបំរើការងារសម្រាប់រយៈពេល ១០(ដប់)ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ក្នុងករណីជនល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មខាងលើ ។

មាត្រា ២៣៩.-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០(ដប់លាន)រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងៗទៀត និងត្រូវដកហូតប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោតសម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ លុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ចំពោះជនណាដែលមានចេតនាធ្វើឱ្យរបើកហិបឆ្នោត ដាច់រហែក ឬរបូតសោឃុំ ឬគ្រឿងសម្ភារៈសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ឬលួច ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

ករណីជនល្មើសជាសមាជិកឬមន្ត្រីបុគ្គលិកនៃគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬមន្ត្រីការិយាល័យបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារនិងមិនឱ្យសាមីខ្លួនចូលបំរើការងារបោះឆ្នោតសម្រាប់រយៈពេល ១០(ដប់)ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះទៅ ។

ក្នុងករណីជនល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មខាងលើ ។

មាត្រា ២៤០.-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតនិងត្រូវដកហូតប័ណ្ណបោះឆ្នោត ឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត សម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំ លុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១២៨ ១២៩ ១៣០ និងមាត្រា ១៣៥ នៃច្បាប់នេះ ។

ប្រសិនបើជនល្មើសនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោល បន្ថែមលើទណ្ឌកម្មខាងលើ ។

មាត្រា ២៤១.-

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងវាក្យខ័ណ្ឌទី ១ និងវាក្យខ័ណ្ឌទី៣មាត្រា ១៣៣ នៃច្បាប់នេះ ។

ក្នុងករណីនៅតែពុំព្រមអនុវត្តតាម ត្រូវដកហូតប័ណ្ណបោះឆ្នោតឬវិញ្ញាបនប័ត្រជំនួសប័ណ្ណបោះឆ្នោត ហើយត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត សម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីការដាក់ឱ្យទំនេរគ្មានបៀវត្សរហូតដល់បណ្តេញចេញពីមុខតំណែង និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០(បួនលាន) រៀល ។

មាត្រា ២៤២.-

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១៥៨ និងមាត្រា ១៥៩ នៃច្បាប់នេះ ។

ក្នុងករណីនៅតែពុំព្រមអនុវត្តតាម ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន) រៀល ។

# ជំពូកទី ១៧
## អន្តរប្បញ្ញត្តិ

មាត្រា ២៤៣.-

ដើម្បីធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទី ១ បន្ទាប់ពីច្បាប់នេះចូលជាធរមាន នាយករដ្ឋមន្ត្រីត្រូវប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ១១(ដប់មួយ)ខែយ៉ាងយូរមុនថ្ងៃបោះឆ្នោត ។

មាត្រា ២៤៤.-

ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទី ១ នេះ ត្រូវយកបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ១៩៩៨ នៅតាមការិយាល័យចុះឈ្មោះអ្នកបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ ធ្វើជាមូលដ្ឋាន ។

បែបបទនិងនីតិវិធីនៃការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតនេះ ត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ ។

មាត្រា ២៤៥.-

មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រងដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទី១នេះ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពីការងារទៅប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត ក្រុងសាមី តាមរយៈអភិបាលស្រុក ខ័ណ្ឌសាមី ក្នុងរយៈពេលយ៉ាងតិច ៧(ប្រាំពីរ)ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន រួចហើយសាមីខ្លួនត្រូវវិលត្រឡប់មកកាន់មុខតំណែងវិញដើម្បីត្រៀមរៀបចំផ្ទេរប្រគល់ការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់ថ្មី ។

ក្នុងពេលដែលមេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រងសុំឈប់ពីមុខតំណែងដើម្បីឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលស្រុក ខ័ណ្ឌត្រូវជ្រើសរើសប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នោះ ឬមន្ត្រីពីសាលាស្រុក ខ័ណ្ឌរបស់ខ្លួន ឬមន្ត្រីឃុំ សង្កាត់ដែលមិនឈរឈ្មោះជាបេក្ខជន ស្នើទៅប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត ក្រុង សាមី ដើម្បីតែងតាំងបណ្តោះអាសន្នជាមេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រងដែលឈរឈ្មោះជាបេក្ខជន រហូតដល់ថ្ងៃប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះ ។

មាត្រា ២៤៦.-

ដើម្បីធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទី ១ បន្ទាប់ពីច្បាប់នេះចូលជាធរមាន គណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាបច្ចុប្បន្ន ត្រូវឧទ្ទេសនាមតំណាងមួយរូបរបស់ខ្លួន ឱ្យចូលក្នុងសមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីដែលសមាជិកណាមួយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទទួលមរណភាព សុំលាឈប់ជាលាយល័ក្ខអក្សរ បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ឬប្រព្រឹត្តមិនត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន និងក្នុងករណីដែលមានគណបក្សនយោបាយសាមីត្រូវបានរំលាយ សមាជិករូបនោះត្រូវផ្លាស់ប្តូរស្របតាមបទប្បញ្ញត្តិដែលមានកំណត់ក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

## ជំពូកទី ១៨
## អវសានប្បញ្ញត្តិ

មាត្រា ២៤៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២៤៨.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

ស ខេង យូ ហុកគ្រី